

របាយការណ៍សង្ខេប

# វេទិកាថ្នាក់តំបន់លើកទី ៣ ស្តីពីមនុស្ស និងព្រៃឈើ

## ពង្រឹងការប្តេជ្ញាចិត្ត ចំពោះផែនការសកម្មភាព សហគមន៍ព្រៃឈើ នៅក្នុងតំបន់អាស៊ី

ថ្ងៃទី ១៩-២០ ខែវិច្ឆិកា ឆ្នាំ ២០១៣ នៅទីក្រុងបាងកក ប្រទេសថៃ

Third Regional Forum for People and Forests
Strengthening commitment to community forestry action plans in Asia

Copyright © RECOFTC January 2014
Bangkok, Thailand

All photos courtesy of RECOFTC

Reproduction of this publication for educational or other non-commercial purposes is authorized without prior written permission from the copyright holders provided the source is fully acknowledged. Reproduction of this publication for resale or other commercial purposes is prohibited without written permission of the copyright holder.

# មាតិកា


សេចក្តីផ្តើម ១
អតីតកាល បច្ចុប្បន្នកាល អនាគតកាល - មេរៀនបទពិសោធន៍ និងបញ្ហាប្រឈមនាពេលអនាគត ៣
ប្រធានបទសំខាន់ៗសម្រាប់ការអនុវត្តន៍ ៧
ការពង្រឹងតួនាទីរបស់ភាគីពាក់ព័ន្ធ ៨
ការយល់ឃើញផ្សេងៗ ចំពោះសហគមន៍ព្រៃឈើ ១៣
ផែនការសកម្មភាពប្រទេសរួមគ្នាដើម្បីពង្រឹងសហគមន៍ព្រៃឈើ ១៤
ប្រទេសកម្ពុជា ១៦
ប្រទេសចិន ២១
ប្រទេសឥណ្ឌូនេស៊ី ២២
ប្រទេសឡាវ ២៤
ប្រទេសមីយ៉ាន់ម៉ា ២៦
ប្រទេសនេប៉ាល់ ២៨
ប្រទេសថៃ ៣០
ប្រទេសវៀតណាម ៣២
ប្រទេសម៉ាឡេស៊ី ៣៤
ប្រទេសហ្វីលីពីន ៣៥
សេចក្តីសន្និដ្ឋាន និងជំហានបន្ទាប់ ៣៧

# សេចក្តីថ្លែងអំណរគុណ

វេទិកាថ្នាក់តំបន់លើកទី៣ ស្តីពីមនុស្ស និងព្រៃឈើ បានរៀបចំឡើងដោយមជ្ឈមណ្ឌលសម្រាប់មនុស្ស និងព្រៃឈើ (RECOFTC) សហការណ៍ជាមួយ នាយកដ្ឋានព្រៃឈើ (Royal Forest Department) បណ្តាញតំបន់អាស៊ីប៉ាស៊ីហ្វិកសម្រាប់ការគ្រប់គ្រង និងស្តារព្រៃឈើដោយនិរន្តរភាព (APFNet) បណ្តាញសង្គមព្រៃឈើអាស៊ាន (ASFN) និងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិ នៃប្រទេសជប៉ុន (JICA) និងគាំទ្រដោយទីភ្នាក់ងារន័រវេសសម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍ (Norad) ទីភ្នាក់ងារកិច្ចសហប្រតិបត្តិការ និងការអភិវឌ្ឍ នៃប្រទេសស្វីស (SDC) និងទីភ្នាក់ងារកិច្ចសហប្រតិបត្តិការសម្រាប់ការអភិវឌ្ឍអន្តរជាតិស៊ុយអែត (Sida)។

អង្គការ RECOFTC សូមថ្លែងអំណរគុណដល់អ្នករៀបចំវេទិកានេះដែលមានដូចជា៖ Phinyada Atchatavivan, Julian Atkinson, Chawpaka Chaosarn, David Gritten, Caroline Liou, Jephraim Oro, Panisara Panupitak, Thippawan Maidee, Detty Saluling, Pimpakarn Serithamarak, Apinita Siripatt, Ramida Thananathachat, Tiamkare Thitithamtada, Ann Jyothis, Subantita Suwan, Nick Wilder និង សូមថ្លែងអំណរគុណដល់ Karen Edwards, Tommy Kristiawan Permadi and Imawan Atmosudirjo ដែលបានចូលរួមចំណែកសម្របសម្រួលក្នុងវិទិកានេះ។ សូមថ្លែងអំណរគុណជាពិសេសដល់ James Bampton, Tint Lwin Thaung, Ronnakorn Triraganon, Yosef Arihadi, Thongsavath Boupha, Edwin Payuan, Bishnu Hari Poudyal, Somying Soontornwong, Nguyen Quang Tan, and Maung Maung Than ដែលបានផ្តល់យោបល់ណែនាំក្នុងការរៀបចំព្រឹត្តិការណ៍នេះ។ យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់អ្នកចូលរួម និងវាគ្មិនទាំងអស់ដែលបានចូលរួមចែករំលែកចំណេះដឹង និងបទពិសោធន៍របស់ខ្លួនក្នុងវេទិកានេះ។

របាយការណ៍នេះរៀបចំចងក្រងដោយលោកស្រី Karen Edwards លោកស្រី Caroline Liou និងលោកស្រី Detty Saluling។

# សេចក្តីផ្តើម

វេទិកាថ្នាក់តំបន់លើកទី៣ ស្តីពីមនុស្ស និងព្រៃឈើ មានការចូលរួមពីសិក្ខាកាមប្រមាណជាង ១០០នាក់ មកពីប្រទេសចំនួន១៥ ផ្សេងៗគ្នាក្នុងតំបន់អាស៊ីប៉ាស៊ីភិច។ ព្រឹត្តិការណ៍នេះបានរៀបចំឡើងក្នុងគោលបំណងដើម្បីពិនិត្យឡើងវិញទៅលើដំណើរការដែលបានអនុវត្តកន្លងមក ព្រមទាំងវាយតម្លៃពីវឌ្ឍនភាព និងមេរៀនបទពសោធន៍បន្តពីវេទិកាថ្នាក់តំបន់លើកទី២ ស្តីពីមនុស្ស និងព្រៃឈើ។ វេទិកានេះប្រព្រឹត្ត ទៅដោយមានការចូលរួមយ៉ាងសកម្ម ពីសំណាក់ក្រុមយុទ្ធសាស្រ្តនៃភាគីពាក់ព័ន្ធសំខាន់ៗ មកពីប្រទេសដែលអង្គការ RECOFTC ប្រតិបត្តិការណ៍ (ប្រទេសកម្ពុជា ចិន ឥណ្ឌូនេស៊ី ឡាវ មីយ៉ាន់ម៉ា នេប៉ាល់ ថៃ វៀតណាម ម៉ាឡេស៊ី និងហ្វីលីពីន) ដើម្បីកំណត់សកម្មភាពស្នូលជាក់ស្តែង និងជាយុទ្ធសាស្រ្ត ក្នុងការប្តេជ្ញាចិត្តលើកកម្ពស់សហគមន៍ព្រៃឈើនាពេលអនាគត។

លោក Boonchob Suthamanuswong ប្រធាននាយកដ្ឋានព្រៃឈើ (Royal Forest Department) ព្រះរាជាណាចក្រថៃបានអញ្ជើញជាកិត្តិយសក្នុងការបើកកម្មវិធីនៃវេទិកាថ្នាក់តំបន់នេះ។ លោកបានមានប្រសាសន៍ថា៖ "ការបង្កើតឱ្យមានសហគមន៍ព្រៃឈើអាចជាដំណោះស្រាយដ៏មានប្រសិទ្ធភាពមួយចំពោះដំណោះដីធ្លីក្នុងតំបន់ដីព្រៃ និងជាមធ្យោបាយមួយដើម្បីលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជន ចូលរួមកាត់បន្ថយការបំផ្លាញព្រៃឈើ និងពង្រឹងអភិបាលកិច្ចល្អ តាមរយៈការយកចិត្តទុកដាក់លើតម្រូវការរបស់ប្រជាជនមូលដ្ឋាន និងចំណេះដឹងរបស់ពួកគេ"។

លោកបណ្ឌិត Tint Lwin Thaung នាយកប្រតិបត្តិអង្គការ RECOFTC បានមានប្រសាសន៍ក្នុងពេលបើកកម្មវិធីនេះដែរថា៖ "ការបង្កើនតំបន់ព្រៃឈើក្រោមការគ្រប់គ្រងរបស់សហគមន៍ គឺជាអាទិភាពចម្បងមួយ ប៉ុន្តែកត្តាសំខាន់ប្រហែលគ្នានេះដែរគឺការគ្រប់គ្រងដោយយកចិត្តទុកដាក់របស់សហគមន៍ ទៅលើព្រៃឈើរបស់ពួកគេ។ នៅពេលប្រជាពលរដ្ឋត្រូវបានគេផ្តល់ឱកាសឱ្យចូលរួមក្នុងការធ្វើសេចក្តីសម្រេចចិត្ត និងទាញយកផលប្រយោជន៍ជាទៀងទាត់ពីព្រៃឈើរបស់ពួកគេ ដែលនេះជាភស្តុតាងបង្ហាញឱ្យឃើញថា ពួកគេបានចូលរួមចំណែកក្នុងការអភិរក្សជីវចម្រុះ កាត់បន្ថយការបំផ្លាញព្រៃឈើ និងគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព"។

វេទិកានេះជាព្រឹត្តិការណ៍ដ៏សំខាន់មួយដែលមានការចូលរួមយ៉ាងសកម្មពីសំណាក់អ្នកចូលរួមទាំងអស់នៅគ្រប់ប្រធានបទនីមួយៗ តាមរយៈការវិភាគស្ថានការណ៍ ការចែករំលែកចំណេះដឹង ការផ្តល់យោបល់ទៅវិញទៅមក និងការកំណត់យកសកម្មភាពអាទិភាព។ គោលបំណងនៃសកម្មភាពទាំងនេះ គឺដើម្បីបង្កើតផែនការសកម្មភាពប្រទេសរួមគ្នា (ពហុភាគី) ដើម្បីពង្រឹងសហគមន៍ព្រៃឈើ និងជម្រុញការប្តេជ្ញាចិត្តឱ្យកាន់តែសកម្មក្នុងការបង្កើនតំបន់ព្រៃឈើ ក្រោមការគ្រប់គ្រងរបស់សហគមន៍ការពង្រឹងការគ្រប់គ្រងរបស់សហគមន៍ទៅលើ ព្រៃឈើរបស់ពួកគេ និងធានាបានថាស្ថាប័ននីមួយៗមានលទ្ធភាពអនុវត្តន៍ច្បាប់គ្រប់គ្រងសហគមន៍ព្រៃឈើក្នុងប្រទេសរបស់ខ្លួន ប្រកបដោយប្រសិទ្ធភាព។ លើសពីនេះទៀត គេបានកែលំអប្រសិទ្ធភាពការងារកាន់តែប្រសើរឡើងពីដំណាក់កាលមួយទៅដំណាក់កាលមួយស្របទៅតាមបទពិសោធន៍ថ្មីៗ និងការលើកជាសំណួរជាក់ស្តែងសម្រាប់ពេលអនាគត។ រាល់គំនិតយោបល់ និងការប្តេជ្ញាចិត្តរបស់អ្នកចូលរួមដែលបានលើកឡើងក្នុងវេទិកាថ្នាក់តំបន់នេះ ត្រូវបានប្រមូលចងក្រង និងត្រូវចែកចាយក្នុងវេទិកាថ្នាក់ជាតិនីមួយដែល នឹងធ្វើឡើងក្នុងឆ្នាំ២០១៤ ក្នុងប្រទេសចំនួន ៦ ផ្សេងៗដូចជា៖ ប្រទេសកម្ពុជា ឥណ្ឌូនេស៊ី វៀតណាម មីយ៉ាន់ម៉ា ថៃ និងឡាវ។

អង្គការ RECOFTC បានរៀបចំវេទិកានេះឡើងដោយសហការណ៍ជាមួយនាយកដ្ឋានព្រៃឈើ នៃប្រទេសថៃ បណ្តាញតំបន់អាស៊ីប៉ាស៊ីហ្វិកសម្រាប់ការគ្រប់គ្រង និងស្តារព្រៃឈើដោយនិរន្តរភាព (APFNet) បណ្តាញសង្គមព្រៃឈើអាស៊ាន (ASFN) និងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន។ វេទិកានេះបានបង្កើតឱ្យមានកម្លាំងចលករជម្រុញដ៏ខ្លាំងក្លា ដើម្បីការផ្លាស់ប្តូរ និងការប្តេជ្ញាចិត្តដាក់លាក់ចំពោះសហគមន៍ព្រៃឈើនៅកម្រិតថ្នាក់ជាតិ។

គោលបំណងរបស់វេទិកានេះគឺដើម្បីបង្កើនការប្តេជ្ញាចិត្តឱ្យបានផុសផុលលើផែនការសម្មភាពប្រទេសរួមគ្នា ដើម្បីពង្រឹងសហគមន៍ព្រៃឈើតាមរយៈ៖

- ការវាយតម្លៃពីវឌ្ឍនភាពរបស់សហគមន៍ព្រៃឈើក្នុងតំបន់ និងស្វែងរកយុទ្ធសាស្រ្តជំនះលើបញ្ហាប្រឈមនានាដើម្បីធានាសុវត្ថិភាពនិងការពារព្រៃឈើ ព្រមទាំងប្រជាពលរដ្ឋដែលអាស្រ័យផលពីព្រៃឈើ
- ជម្រុញអោយមានការចាត់អាទិភាពរួមដើម្បីពង្រឹងសហគមន៍ព្រៃឈើ ការជម្រុញភាពជាដៃគូ និងការសម្របសម្រួលនៅគ្រប់វិស័យ
- បង្កើនការប្តេជ្ញាចិត្តឱ្យបានផុសផុលលើផែនការសកម្មភាពប្រទេសរួមគ្នា ដើម្បីពង្រឹងសហគមន៍ព្រៃឈើដែលជាអាទិភាពដើម្បីបង្កើនតំបន់ព្រៃឈើក្រោមការគ្រប់គ្រងរបស់សហគមន៍ និងការពង្រឹងការគ្រប់គ្រងឱ្យកាន់តែសកម្មរបស់សហគមន៍ទៅលើព្រៃឈើរបស់ពួកគេ ហើយធានាបានថាស្ថាប័នរបស់ពួកគេមានសមត្ថភាពក្នុងការអនុវត្តច្បាប់គ្រប់គ្រងព្រៃឈើនៅក្នុងប្រទេសប្រកបដោយប្រសិទ្ធភាព ។


local
people

# អតីតកាល បច្ចុប្បន្នកាល និងអនាគតកាល

## មេរៀនបទពិសោធន៍ និងបញ្ហាប្រឈមនាពេលអនាគត

លោក Preecha Siri ប្រធានសហគមន៍ព្រៃឈើ Ban Huay Hin Lahd Nai ក្នុងប្រទេសថៃ និងលោកស្រី Isabelita Austria ប្រធានផ្នែកគ្រប់គ្រងសហគមន៍ព្រៃឈើ នៃនាយកដ្ឋានគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន ( Department of Environment and Natural Resource ) របស់ប្រទេសហ្វីលីពីន បានលើកឡើងពីដំណើររឿងនៃការផ្លាស់ប្តូរ ( stories of change ) ដោយផ្តោតជាចម្បងថា សហគមន៍ព្រៃឈើអាចសម្រេចបានលទ្ធផលជាផ្លែផ្កាជាក់ស្តែងទៅបានអាស្រ័យលើលក្ខខណ្ឌអំណោយផល និងមានបរិយាកាសគាំទ្រ។ អ្នកទាំងពីរបានលើកយកបទពិសោធន៍ពីទិដ្ឋភាពផ្សេងគ្នានៃប្រទេសទាំងពីរ (សហគមន៍មូលដ្ឋាន និងរដ្ឋាភិបាលដោយបានបង្ហាញពីតម្រូវការចាំបាច់ នាពេលបច្ចុប្បន្ន ដើម្បីឆ្លើយតបទៅនឹងការអំពាវនាវ ឱ្យមានការរៀបផែនការ និងការពង្រីកសហគមន៍ព្រៃឈើនៅកម្រិតតំបន់ទេសភាព ព្រមទាំងធានាឱ្យបាននូវលក្ខខណ្ឌសមស្រប និងការលើកទឹកចិត្តក្នុងការបង្កើតផែនការនេះ។ បន្ទាប់មក លោកបណ្ឌិត David Gritten មន្ត្រីកម្មវិធីជាន់ខ្ពស់របស់អង្គការ RECOFTC បានលើកឡើងពីបញ្ហាប្រឈមនានា ដែលជាឧបសគ្គរាំងស្ទះដល់ការសម្រេចបានជោគជ័យនាពេលអនាគតក្នុងការអនុវត្តសហគមន៍ព្រៃឈើ។






# សហគមន៍មូលដ្ឋានក្នុងប្រទេសថៃសម្រេចបានជោគជ័យក្នុងសហគមន៍ព្រៃឈើរបស់ពួកគេ

លោក Preecha Siri បានលើកឡើងដោយសង្ខេបពីបទពិសោធន៍របស់គាត់ទាក់ទងទៅនឹងប្រសិទ្ធភាពក្នុងការការពារ និងប្រើប្រាស់ព្រៃឈើ ប្រកបដោយនិរន្តរភាពពីសំណាក់ប្រជាសហគមន៍មូលដ្ឋានថា នៅពេលដែលពួកគេបានទទួលសិទ្ធិក្នុងការគ្រប់គ្រងព្រៃឈើរបស់ពួកគេ នឹងនាំមកនូវផលប្រយោជន៍ដល់មូលដ្ឋាន ប្រទេសជាតិ និងដល់ពិភពលោកទាំងមូល[1]។

ក្នុងន័យនេះ សហគមន៍របស់គាត់ បានសម្របខ្លួនយ៉ាងមានប្រសិទ្ធភាពក្នុងការបន្សីគ្នារវាង ប្រព័ន្ធនៃការធ្វើចំការវិលជុំនៃតំបន់ខ្ពង់រាបដីសើម ការចិញ្ចឹមឃ្មុំ ការដាំទំពាំង និងការដាំតែប្រពៃណីជាមួយនឹងការអភិរក្សព្រៃឈើ ដោយបង្ហាញអំពីគំរូនៃភាពជោគជ័យលើការគ្រប់គ្រងប្រព័ន្ធអេកូឡូស៊ី។ ការផ្តួចផ្តើមបង្កើតគម្រោងបង្កើនប្រាក់ចំនូល បានបង្កើតឱ្យមានមូលនិធិសហគមន៍ និងជានានិរន្តរភាពសហគមន៍ផងដែរ ។

សហគមន៍ Ban Huay Hin Lahd Nai បានទទួលពានរង្វាន់អន្តរជាតិជាច្រើន ដែលនេះឆ្លុះបញ្ចាំងពីការខិតខំប្រឹងប្រែងរបស់ពួកគេក្នុងកិច្ចការពារព្រៃឈើនៅថ្នាក់មូលដ្ឋាន ដោយធ្វើការងាររួមជាមួយភូមិចំនួន ១៦ ផ្សេងទៀត នៅកម្រិតតំបន់ទេសភាពក្នុងប្រទេសថៃ។ ដូច្នេះសហគមន៍ដែលអាស្រ័យផលលើព្រៃឈើ ត្រូវមើលឃើញពីគុណតម្លៃរបស់វា និងជាមួយគ្នានេះដែរគឺការទទួលខុសត្រូវនិងការប្តេជ្ញាចិត្តការពារនៅក្នុងមូលដ្ឋាន ដែលឈានទៅពង្រីកតំបន់សហគមន៍ព្រៃឈើ ក្រោមការគ្រប់គ្រងរបស់សហគមន៍មូលដ្ឋានក្នុងតំបន់ទេសភាព Ban Huay Hin Lahd Nai។

# មេរៀនបទពិសោធន៍ស្តីពីការអភិវឌ្ឍកម្មវិធីព្រៃឈើសង្គមនៅក្នុងប្រទេសហ្វីលីពីន

លោកស្រី Isabelita Austria បានធ្វើបទបង្ហាញពីមេរៀនបទពិសោធន៍ពីអតីតកាលរហូតដល់បច្ចុប្បន្ន ស្តីពីសហគមន៍ព្រៃឈើក្នុងប្រទេសហ្វីលីពីន ដោយបានលើកឡើងពីការផ្លាស់ប្តូរជាប្រវត្តិសាស្ត្រ ដែលបាននាំទៅដល់ការពង្រីកតំបន់សហគមន៍ព្រៃឈើរួមទាំងការបង្កើនរយៈពេលនៃសិទ្ធិកាន់កាប់ ដោយប្តូរពីកិច្ចព្រមព្រៀងជា លក្ខណៈបុគ្គលរយៈពេលខ្លី ទៅជាកិច្ចព្រមព្រៀងសហគមន៍រយៈពេលវែងវិញ។

នៅកំលុងទសវត្សរ៍ឆ្នាំ១៩៧០ កម្មវិធីព្រៃឈើរបស់រដ្ឋាភិបាល (government-led people-oriented forestry programs) បានធ្វើការឆ្លើយតបទៅនឹងការធ្លាក់ចុះគម្របព្រៃឈើ កំណើនប្រជាជន ភាពក្រីក្រនៅក្នុងតំបន់ខ្ពង់រាប ការកើនឡើងនូវតម្រូវការប្រើប្រាស់ឈើ និងស្បៀងអាហារ និងភាពបរាជ័យលើវិធានការទប់ស្កាត់ការកាន់កាប់ព្រៃឈើ។

នៅកំលុងទសវត្សរ៍ឆ្នាំ៨០ កម្មវិធីនេះត្រូវបានរួមបញ្ចូលទៅក្នុងកម្មវិធីសមាហរណកម្មសហគមន៍ព្រៃឈើសង្គម (Integrated Social Forestry program) និងចេញសិទ្ធិកាន់កាប់ដីធ្លីលក្ខណៈបុគ្គលតាមរយៈការចេញប័ណ្ណកិច្ចសន្យាកម្មសិទ្ធិ Certificate of Stewardship Contract។ កម្មវិធីអភិវឌ្ឍន៍តំបន់ខ្ពង់រាបរយៈពេល ១៥ ឆ្នាំ ត្រូវបានធ្វើការសាកល្បងនៅ ១៦ កន្លែង ផ្សេងៗគ្នាទូទាំងប្រទេស ដែលគាំទ្រដល់ការស្រាវជ្រាវនៃគម្រោងសមាហរណកម្មព្រៃឈើសង្គម។ ទោះជាយ៉ាងនេះក៏ដោយ ការគ្រប់គ្រងជាលក្ខណៈបុគ្គលក្នុងសមាហរណកម្មព្រៃឈើសង្គម មិនបានបង្កើនសកម្មភាពរបស់សហគមន៍ឱ្យបានរឹងមាំនោះទេ។ ជាមួយគ្នានេះដែរ ផលិតផលព្រៃឈើ មិនត្រូវបានដំណើរការល្អនៅលើទីផ្សារឡើយ។

ក្នុងលិខិតបង្គាប់ការលេខ ២៦៣ ដែលបានចុះហត្ថលេខានៅឆ្នាំ១៩៩៥ បានអនុម័តទៅលើការគ្រប់គ្រងព្រៃឈើសហគមន៍ដែលជាយុទ្ធសាស្ត្រជាតិសម្រាប់ការអភិវឌ្ឍដីព្រៃ និងធនធានរបស់គេប្រកបដោយនិរន្តរភាព។ នៅមានការគាំទ្រតិចតួចនៅឡើយក្នុងការបង្កើតប្រព័ន្ធព័ត៌មានទីផ្សារនៅថ្នាក់មូលដ្ឋាន ចំពោះការផ្សព្វផ្សាយផលិតផលបានមកពីព្រៃសហគមន៍ ដែលជាហេតុធ្វើឱ្យផលិតផលរបស់សហគមន៍មិនសូវមានតម្លៃនៅលើទីផ្សារ។ ការស្វែងរកទីផ្សារ មិនត្រូវបានទទួលការចាប់អារម្មណ៍ប៉ុន្មានឡើយនៅដើមទសវត្សរ៍ទី ៩០ ប៉ុន្តែបច្ចុប្បន្ននេះសហគមន៍បានចាប់អារម្មណ៍ទៅលើប្រព័ន្ធព័ត៌មានទីផ្សារ។

[1] United Nations Forum on Forests 2012, 2012-2013 Forest Heroes Award Winners, accessed 13 January 2013, <http://www.un.org/esa/forests/forest-heroes/winners.html>.

# បញ្ហាប្រឈមនាពេលអនាគត៖ មូលដ្ឋានគ្រឹះនៃភាពជោគជ័យរបស់សហគមន៍ព្រៃឈើ

លោកបណ្ឌិត David Gritten បានលើកឡើងថា ការបង្កើតសហគមន៍ព្រៃឈើ គឺជាជម្រើសដ៏សមស្របបំផុតសម្រាប់ការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តរភាពនៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិច និងជួយលើកកម្ពស់សេដ្ឋកិច្ច បរិស្ថាន និងសង្គមនៅថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិដោយរួមបញ្ចូលទាំង៖

១. ការលើកកម្ពស់របរចិញ្ចឹមជីវិត និងបំពេញតម្រូវការប្រើប្រាស់របស់គ្រួសារ (អុសដុត វាលស្មៅចិញ្ចឹមសត្វ និងឈើសំណង់។ល។)

២. កាត់បន្ថយការបំផ្លាញព្រៃឈើ និងបង្កើនគុណភាព និងស្ថានភាពព្រៃអោយកាន់តែប្រសើរ(ទំហំឈើកាន់តែធំចាក់ឫសគល់កាន់ តែរឹងមាំ ការលូតលាស់របស់គម្របព្រៃឈើ និងការកើនឡើងនៃជីវចម្រុះ)

៣. ការពង្រឹងអភិបាលកិច្ច និងសិទ្ធិសម្រេចចិត្តរបស់ប្រជាជនមូលដ្ឋាន។

ទោះបីជាយ៉ាងនេះក៏ដោយ កន្លងមកការអនុវត្តសហគមន៍ព្រៃឈើមិនទាន់សម្រេចបានទៅតាមគោលបំណងនៅឡើយ។ នេះបញ្ជាក់ឱ្យឃើញពីបញ្ហាប្រឈមនានានៅពេលអនាគតក្នុងតំបន់ទាំងមូលដូចជា កំណើនប្រជាជន កំណើននគរូបនីយកម្ម ការប្រែប្រួលអាកាសធាតុ និងអស្ថេរភាពនៃតម្លៃស្បៀងអាហារជាដើម។ តាមរយៈសហគមន៍ព្រៃឈើ គេអាចជួយដោះស្រាយបញ្ហាទាំងនេះបានប្រសិនបើគេយកចិត្តទុកដាក់ និងអនុវត្តនូវរូបមន្តដូចខាងក្រោមនេះ៖

susCF = T + 2aR + aC + M

susCF (និរន្តរភាពសហគមន៍ព្រៃឈើ)

T (សិទ្ធិកាន់កាប់)

2aR (ច្បាប់ និងធនធានសមស្រប)

aC (សមត្ថភាពសមស្រប)

M (ទីផ្សារ)

និរន្តរភាពរបស់សហគមន៍ព្រៃឈើផ្តើមចេញពីសិទ្ធិកាន់កាប់ (Tenure)។ សិទ្ធិកាន់កាប់មានសារៈសំខាន់ច្រើនយ៉ាង ដូចជាការធានាមិនឱ្យមានការរំលោភបំពាន ការជម្រុញឱ្យមានការទទួលខុសត្រូវកាន់តែប្រសើរឡើងចំពោះការកាន់កាប់ដី ព្រមទាំងជួយសម្រួលដល់ការវិនិយោគដែលនឹងទទួលផលតបស្នងកាន់តែប្រសើរ ទាំងក្នុងវិស័យសេដ្ឋកិច្ច វិស័យសង្គម និងបរិស្ថានផងដែរ។

aR (ច្បាប់សមស្រប) ទី១ អាស្រ័យទៅលើកត្តាជាក់ស្តែងនៅទូទាំងតំបន់ ដែលបទបញ្ញត្តិមួយចំនួន មានឥទ្ធិពលអវិជ្ជមានលើសកម្មភាពរបស់សហគមន៍ និងព្រៃឈើ ដែលនេះនាំឱ្យបរាជ័យក្នុងការទាញយកផលប្រយោជន៍ពីព្រៃឈើទាំងនេះ ព្រមទាំងដាក់បន្ទុកកាន់ តែច្រើនឡើងដល់សហគមន៍។ បន្ថែមពីលើនេះទៀតមន្ត្រីរដ្ឋាភិបាលត្រូវតែត្រួតពិនិត្យច្បាប់ទាំងឡាយណាដែលផ្តល់ផលប្រយោជន៍តិចតួចដល់សហគមន៍។ ច្បាប់ដែលសមស្របត្រូវតែដាក់ឱ្យអនុវត្តន៍ ដើម្បីបង្កើតឱ្យមានបរិយាកាសគាំទ្រចំពោះសហគមន៍ព្រៃឈើ។ aR (ធនធានសមស្រប) ទី ២ គឺសំដៅលើធនធានសមស្របដែលមានន័យថា ព្រៃឈើដែលផ្តល់ទៅឱ្យសហគមន៍កាន់កាប់ត្រូវតែជាប្រភេទព្រៃដែលមានធនធានធម្មជាតិពិតប្រាកដ ដោយជៀសវាងការប្រគល់ជូនដីព្រៃទាំងឡាយណាដែលខូចគុណភាព និងរេចរឹល។ កត្តាជាក់ស្តែងដែលបញ្ជាក់ពីជោគជ័យរបស់សហគមន៍ព្រៃឈើ គឺស្តែងចេញតាមរយៈការប្រកបរបរចិញ្ចឹមជីវិតដោយទាញយកផលប្រយោជន៍ពីព្រៃឈើ ហើយជោគជ័យនេះអាចសម្រេចទៅបានផ្តើមចេញពី ការមានសិទ្ធកាន់កាប់ព្រៃឈើនិងសិទ្ធកាន់កាប់ដីធ្លី។

aC (សមត្ថភាពសមស្រប) ផ្អែកលើភាពជាក់ស្តែង ដើម្បីគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាពទៅបាន សហគមន៍ និងមន្ត្រីរដ្ឋាភិបាលក្នុងតំបន់សហគមន៍ព្រៃឈើចំបាច់ត្រូវមានសមត្ថភាពផ្នែកបច្ចេកវិទ្យា និងការទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយ។ ព័ត៌មានទាំងនេះ នឹងជួយជម្រុញឱ្យសហគមន៍យល់ដឹងពីសារៈសំខាន់ក្នុងការចូលរួមធ្វើការសម្រេចចិត្តអ្វីមួយ។ ចុងក្រោយគឺ M (ទីផ្សារ) ដែលសហគមន៍ត្រូវការជាចំបាច់ដើម្បីលក់ផលិតផលព្រៃឈើរបស់ពួកគេ។

ជារួម ការរួមបញ្ចូលគ្នានូវកត្តាទាំងឡាយដែលបានរៀបរាប់ខាងលើនេះ នឹងធ្វើឱ្យសហគមន៍ព្រៃឈើអាចសម្រេចបាននូវគោលដៅរបស់ពួកគេ ព្រមទាំងជួយដល់សង្គមទាំងមូល ឆ្លើយតបទៅនឹងបញ្ហាប្រឈមនានានៅពេលអនាគតផងដែរ។


Security of tenure as the fondation of sustainable of CF
openness by different stakeholder is the key to effective participation collaboration.
Long-term planning is essential for making it possible and desirable for people to stay and manage the forest instead of moving to the cities.
Give community rights to harvest timber from forests (simple procedures / free tax / technology instuctions)
Marketing the forest products & services produced from CF; CF developments in Socio-Economic developments.

# ប្រធានបទសំខាន់ៗសម្រាប់ការអនុវត្តន៍

វេទិកាថ្នាក់តំបន់លើកទី៣ បានផ្តោតសំខាន់ទៅលើការបង្កើនប្រសិទ្ធភាពនៃទំនាក់ទំនងរវាងអ្នកចូលរួមទាំងអស់ ដែលមកពីប្រទេសផ្សេងៗគ្នា ដើម្បីចែករំលែកនូវមេរៀនបទពិសោធន៍ និងការធ្វើការសន្និដ្ឋានទៅលើបញ្ហាប្រឈមនានា ដែលនឹងត្រូវជួបប្រទះក្នុងការអនុវត្តន៍សហគមន៍ព្រៃឈើនៅពេលអនាគត។ តាមរយៈការពិភាក្សាទៅវិញទៅមក គេបានកណត់នូវប្រធានបទរួម និងផ្នែកសំខាន់ៗមួយចំនួន សម្រាប់ការអនុវត្តដូចជា៖

**សុវត្ថិភាពសិទ្ធកាន់កាប់ព្រៃឈើ៖** ត្រូវបានចាត់ទុកជាគោលការណ៍ចម្បង និងជាមេរៀនសំខាន់មួយសម្រាប់សហគមន៍ព្រៃឈើក្នុងការឈានទៅរកភាពជោគជ័យ ហើយបញ្ហានេះនៅតែជារបៀបវារៈចម្បងចំពោះប្រទេសមួយចំនួនដែលសិទ្ធកាន់កាប់នៅមានដែនកំណត់នៅឡើយ ហើយគោលនយោបាយមួយចំនួន នៅមានផលអវិជ្ជមានដល់ការទាញយកផលប្រយោជន៍ ពីព្រៃឈើ។

**ការយកគោលនយោបាយទៅអនុវត្តជាក់ស្តែង៖** គេមិនអាចសន្និដ្ឋានទុកជាមុនបានថា ប្រសិនបើក្របខណ្ឌគោលនយោបាយត្រូវបានដាក់ឱ្យប្រើប្រាស់ សហគមន៍ព្រៃឈើនឹងអនុវត្តបានប្រកបដោយប្រសិទ្ធភាពនោះឡើយ។ ការផ្តល់ដីកម្មសិទ្ធិ និងការចុះកិច្ចព្រមព្រៀងដល់សហគមន៍នៅមិនទាន់មានភាពរលូននៅឡើយ។ ប្រសិទ្ធភាពនៃការអនុវត្តន៍ក្របខណ្ឌគោលនយោបាយក៏ត្រូវបានលើកយកមក ពិភាក្សានៅក្នុងវេទិកានេះដែរ។

**ការរួមបញ្ចូលគ្នាពីផ្នែកតូចៗទៅក្នុងកម្រិតតំបន់ទេសភាព៖** គេបានទទួលស្គាល់ថា នៅតំបន់ខ្លះនៃប្រទេសមួយចំនួន ការផ្តល់សិទ្ធិក្នុងការគ្រប់គ្រងព្រៃឈើទៅដល់សហគមន៍មានការកើនឡើងក៏ដោយ ក៏នៅមិនទាន់ឈានដល់កម្រិតតំបន់ទេសភាពនៅឡើយ។ គេចាំបាច់ត្រូវបញ្ចូលសហគមន៍ព្រៃឈើទៅក្នុងយុទ្ធសាស្ត្រគ្រប់គ្រងការប្រើប្រាស់ដីធ្លី ទៅក្នុងការរៀបចំផែនការដីធ្លីដោយមានការចូលរួម។ កត្តានេះតម្រូវឱ្យមានការចូលរួមសហការណ៍ពីអន្តរវិស័យសំខាន់ៗ។ ផលប្រយោជន៍ដែលទទួលបានសម្រាប់សហគមន៍ព្រៃឈើ និងវិស័យពាក់ព័ន្ធដ៏ទៃទៀតត្រូវមានភាពច្បាស់លាស់។ បញ្ហានេះក៏ជារបៀបវារៈដ៏សំខាន់មួយដែលត្រូវបានលើកយកមកពិភាក្សាក្នុងវេទិកាថ្នាក់តំបន់នេះដែរ។

**ការបញ្ចូលបញ្ហាសហគមន៍ព្រៃឈើទៅក្នុងវិស័យផ្សេងៗ និងក្នុងរបៀបវារៈជាសកល៖** ផលប្រយោជន៍របស់សហគមន៍ព្រៃឈើ និងបញ្ហាមួយចំនួនទៀតចាំបាច់ត្រូវធ្វើការផ្សព្វផ្សាយទៅក្នុងរបៀបវារៈ និងកិច្ចពិភាក្សាកម្រិតសកល ដូចជាការប្រែប្រួលអាកាសធាតុជាដើម ដែលនេះនឹងឈានទៅរកការពង្រីកតំបន់ស្ថិតនៅក្រោមការគ្រប់គ្រងរបស់សហគមន៍ព្រៃឈើ និងដើម្បីលើកកម្ពស់សុវត្ថិភាពសិទ្ធកាន់កាប់។ យុទ្ធសាស្ត្រក្នុងការពង្រឹងទំនាក់ទំនងឱ្យកាន់តែប្រសើរឡើងរវាងអ្នកធ្វើការងារជាមួយសហគមន៍ព្រៃឈើ និងវិស័យផ្សេងៗទៀតត្រូវបានកំណត់ជាបញ្ហាមួយដែលចាំបាច់ត្រូវលើកយកមកពិភាក្សានៅក្នុងវេទិកានេះ។

**ឆ្ពោះទៅរកផលប្រយោជន៍សេដ្ឋកិច្ច និងការធ្វើពាណិជ្ជកម្មផលិតផល និងសេវាកម្មរបស់សហគមន៍ព្រៃឈើ៖** នេះជាប្រធានបទមួយដែលត្រូវបានលើកយកមកពិភាក្សាវែកញែកក្នុងវេទិកា ហើយបានឆ្លុះបញ្ចាំងស៊ីជម្រៅចំពោះការប្តេជ្ញាចិត្តរបស់ប្រទេសនីមួយៗ។ ការផ្លាស់ប្តូរពីការប្រកបរបរចិញ្ចឹមជីវិតតាមប្រពៃណីរបស់សហគមន៍ព្រៃឈើ ហើយផ្តោតទៅលើការធ្វើ អាជីវកម្ម គឺជាកត្តាចាំបាច់។




# ការពង្រឹងតួនាទីរបស់ភាគីពាក់ព័ន្ធ

ក្រោយពីការកំណត់ប្រធានបទរួមគ្នានៅថ្នាក់តំបន់ និងការកំណត់យកវិស័យសំខាន់ៗសម្រាប់លើកយកមកអនុវត្តរួចមក អ្នកចូលរួមបានប្រមូលផ្តុំគ្នានៅក្នុងក្រុមរបស់ខ្លួន។ ក្រុមនីមួយៗបានពិភាក្សាទៅលើវិស័យសំខាន់ៗសម្រាប់អនុវត្តនាពេលអនាគត ដែលស្តែងចេញពីទស្សនវិស័យផ្ទាល់របស់ក្រុមពួកគេនិងការកំណត់យកការប្តេជ្ញាចិត្ត សំខាន់ៗដែលនឹងត្រូវអនុវត្តន៍ដោយក្រុមខ្លួន ដើម្បីពង្រឹងសហគមន៍ព្រៃឈើ។

| ភាគីពាក់ព័ន្ធ | តួនាទីនាពេលអនាគត | ការប្ដេជ្ញាចិត្តជាអាទិភាព |
|---|---|---|
| រដ្ឋាភិបាលថ្នាក់ជាតិ | សម្របសម្រួល និងធ្វើសុខដុមនីយកម្ម គោលនយោបាយ ផែនការយុទ្ធសាស្ត្រជាតិ និងថវិកា ដោយបញ្ចូលសហគមន៍ព្រៃឈើទៅក្នុងគ្រប់វិស័យពាក់ព័ន្ធ | • ធ្វើបច្ចុប្បន្នភាព និងពិនិត្យឡើងវិញនូវគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តទាំងឡាយណាដែលពាក់ព័ន្ធ<br>• លើកកម្ពស់ភាពជាតំណាងរបស់សហគមន៍ និងក្រុមដែលមានសម្លេងភាគតិចទៅក្នុងក្រុមការងារថ្នាក់ជាតិ |
| ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងបរិស្ថាន | បង្កើតគោលនយោបាយប្រកបដោយប្រសិទ្ធភាពដែលគាំទ្រដល់សហគមន៍ព្រៃឈើ និង លើកកម្ពស់របរចិញ្ចឹមជីវិតអាស្រ័យផលពីព្រៃឈើ | • ផ្ដល់មូលនិធិ និងសេវាគាំទ្រគ្រប់គ្រាន់ដល់សហគមន៍ព្រៃឈើ<br>• បង្កើតភាពជាដៃគូប្រកបដោយនិរន្តរភាពជាមួយភាគីពាក់ព័ន្ធ<br>• ពង្រឹងប្រព័ន្ធគ្រប់គ្រងព័ត៌មាន និងមជ្ឈមណ្ឌលចែករំលែកចំណេះដឹងដល់សហគមន៍ព្រៃឈើ |
| រដ្ឋាភិបាលមូលដ្ឋាន | ដាក់បទបញ្ញាអនុវត្ត និងផ្ដល់សេវាកម្មបច្ចេកទេសដល់សហគមន៍ព្រៃឈើ | • ពង្រឹងសមត្ថភាពផ្ទៃក្នុង ដើម្បីផ្ដល់សេវាកម្មបច្ចេកទេសមានគុណភាពខ្ពស់<br>• បញ្ចូលសហគមន៍ព្រៃឈើទៅក្នុងផែនការអភិវឌ្ឍ និងផែនការប្រើប្រាស់ដីធ្លីរបស់រដ្ឋាភិបាលមូលដ្ឋាន ដោយរួមបញ្ចូលទាំងថវិការគាំទ្រផងដែរ<br>• កែលម្អសមាហរណកម្មរវាងសហគមន៍ និងក្រសួងជំនាញ ដើម្បីធ្វើការផ្ដល់ព័ត៌ឱ្យមានប្រសិទ្ធិភាព ចំពោះបញ្ហាកើតឡើង ការផ្លាស់ប្ដូរមេរៀនគ្នាទៅវិញទៅមក និងការរៀបចំគោលនយោបាយ |
| វិស័យឯកជន | រក្សានិរន្តរភាពផលិតផលរបស់សហគមន៍ទៅកាន់ទីផ្សារ ឈ្មួញកណ្ដាល និង សហគ្រិន | • បង្កើតភាពជាដៃគូយូរអង្វែង និងជំនួញនៅសហគមន៍ដោយផ្អែកលើគោលការណ៍ឈ្នះឈ្នះ<br>• ផ្ដល់ជំនាញចំបាច់ដល់សហគមន៍គោលដៅដើម្បីឱ្យពួកគេមានសមត្ថភាពក្នុងការរៀបចំស្ថាប័ន ការគ្រប់គ្រងថវិកានិងការស្វែងរកទីផ្សារដោយខ្លួនឯង |
| អង្គការអន្តរជាតិ | បង្កើតចំណេះដឹង និងផ្ដោតទៅលើវិធីសាស្ត្រក្នុងការដោះស្រាយបញ្ហាដែលនឹងកើតមានក្នុងជំហានបន្ទាប់ដោយរួមមាន ការធ្វើពាណិជ្ជកម្មទៅលើសេវាកម្ម និងផលិតផលរបស់សហគមន៍ព្រៃឈើ | • គាំទ្រគោលនយោបាយ និងការអនុវត្តន៍ដោយមានការចូលរួមនៅក្នុងប្រទេស<br>• បន្តកសាងសមត្ថភាពដល់សហគមន៍ព្រៃឈើ<br>• បង្កើនការសម្របសម្រួលរវាងម្ចាស់ជំនួយនៅថ្នាក់ជាតិ និងអន្តរជាតិទៅដល់សហគមន៍ព្រៃឈើ |
| អ្នកស្រាវជ្រាវ និង គ្រឹះស្ថានឧត្តមសិក្សា | ភ្ជាប់ការស្រាវជ្រាវ និងរបកគំហើញទាក់ទងទៅនឹងការអនុវត្តល្អ ដើម្បីជាព័ត៌មានដល់អ្នកធ្វើសេចក្ដីសម្រេចចិត្ត និងការបង្កើតគោលនយោបាយពាក់ព័ន្ធទៅនឹងសហគមន៍ព្រៃឈើ | • ធ្វើការស្រាវជ្រាវ និងចែកចាយលទ្ធផលទទួលបាន<br>• បញ្ជ្រាបការសិក្សាស្រាវជ្រាវសហគមន៍ព្រៃឈើទៅក្នុងគ្រឹះស្ថានឧត្តមសិក្សា<br>• ផ្សព្វផ្សាយព័ត៌មានទៅកាន់ក្រុមគោលដៅសម្រាប់ការរៀបចំ និងកែប្រែគោលនយោបាយ |
| ប្រព័ន្ធផ្សព្វផ្សាយ | ពង្រឹងទំនាក់ទំនងទៅវិញទៅមកចំពោះបញ្ហាផ្សេងៗទាក់ទងទៅនឹងព្រៃឈើ | • សរសេរអត្ថបទព័ត៌មានទាំងឡាយណាដែលបង្ហាញពីឥទ្ធិពលវិជ្ជមានរបស់សហគមន៍ព្រៃឈើ<br>• ផ្សព្វផ្សាយមតិរបស់តំណាងប្រជាជនមូលដ្ឋាន ទៅកាន់ភាគីពាក់ព័ន្ធ<br>• បង្កើនការផ្សព្វផ្សាយរបាយការណ៍របស់ភាគីពាក់ព័ន្ធទាំងអស់ឱ្យមានតុល្យភាព |
| សង្គមស៊ីវិល | បន្តតួនាទីរបស់ខ្លួនក្នុងការភ្ជាប់ទំនាក់ទំនង ព្រមទាំងពាំនាំសម្លេងទៅវិញទៅមក រវាងអ្នកធ្វើការជាមួយសហគមន៍ព្រៃឈើ និងអ្នកបង្កើតគោលនយោបាយ | • ស្វែងរកការគាំទ្របន្ថែម ចំពោះគោលនយោបាយដែលផ្ដោតលើផលប្រយោជន៍របស់សហគមន៍ និងប្រជាជន<br>• កិច្ចសហប្រតិបត្តិការណ៍រឹងមាំជាមួយភាគីពាក់ព័ន្ធនានា<br>• បន្តគាំទ្រការកសាងសមត្ថភាពដល់សហគមន៍ |
| សហគមន៍ | ពង្រឹង និងពង្រីកបណ្ដាញសហគមន៍ដើម្បីចងក្រងសម្លេងរួម និងធ្វើសកម្មភាពរួមគ្នាព្រមទាំងផ្ទេរជំនាញដឹកនាំទៅអ្នកជំនាន់ក្រោយ | • បង្កើតមជ្ឈមណ្ឌលសិក្សានៅសហគមន៍ និងចែករំលែកចំណេះដឹងទៅអ្នកដទៃ<br>• ជម្រុញឱ្យរដ្ឋាភិបាលមានទំនួលខុសត្រូវចំពោះសុវត្ថិភាពសិទ្ធកាន់កាប់ដីធ្លី និងព្រៃឈើ<br>• កសាងសមត្ថភាពដល់អ្នកជំនាន់ក្រោយដើម្បីដឹកនាំការគ្រប់គ្រងសហគមន៍ព្រៃឈើ និងសហគ្រិនភាព |

# ការដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវផែនការយុទ្ធសាស្ត្រថ្មីឆ្នាំ ២០១៣-២០១៨ របស់ RECOFTC



RECOFTC បានដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវផែនការយុទ្ធសាស្ត្រថ្មីឆ្នាំ ២០១៣-២០១៨ របស់ខ្លួនក្នុងវេទិកាថ្នាក់តំបន់លើកទី៣ នេះផងដែរ។ បន្ថែមទៅលើជំហានយុទ្ធសាស្ត្រកន្លងមកដែលទទួលបានជោគជ័យជាផ្លែផ្កានោះ ផែនការយុទ្ធសាស្ត្រថ្មី (២០១៣-២០១៨) ក្រោមចំនងជើង៖ People and forests for a greener future – Empowering local people to effectively and equitably engage in the sustainable management of forested landscapes បានផ្តោតការយកចិត្តទុកដាក់កាន់តែខ្លាំងឡើង ទៅលើលទ្ធផលយុទ្ធសាស្ត្រ នៅក្នុងផ្នែកទាំងបួនដែលរួមមាន៖ ១) សុវត្ថិភាពសហគមន៍ព្រៃឈើ (Securing Community Forestry) ២)ការលើកកម្ពស់ការប្រកបរបរចិញ្ចឹមជីវិត និងទីផ្សារ (Enhancing livelihoods and Markets) ៣)មនុស្សព្រៃឈើ និងការប្រែប្រួលអាកាសធាតុ (People, Forests and Climate Change) និង៤) ការដោះស្រាយជម្លោះក្នុងវិស័យព្រៃឈើ (Transforming Forest Conflicts)។ ផ្នែកទាំងបួននេះក៏គ្របដណ្តប់ទៅលើបញ្ហាផ្សេងទៀតដែលរួមមាន យុទ្ធសាស្ត្រតំបន់ទេសភាព សន្តិសុខស្បៀង សុវត្ថិភាពទឹក និងថាមពលជីវម៉ាស។

យុទ្ធសាស្ត្រនេះផ្តោតទៅលើសិទ្ធជាមូលដ្ឋាន និងអាស្រ័យលើគោលការណ៍ ៣ យ៉ាងគឺ ៖ សុវត្ថិភាពសិទ្ធិរឹងមាំ អភិបាលកិច្ចល្អ និងផលប្រយោជន៍សមធម៌ ។ ហើយគោលការណ៍បីយ៉ាងនេះកំពុងត្រូវបានពង្រឹង រួមជាមួយនឹងការផ្តោតការយកចិត្តទុក ដាក់កាន់តែខ្លាំងឡើងទៅលើយេនឌ័រ ផលប្រយោជន៍សង្គម ការពង្រឹងភាពជាអ្នកដឹកនាំក្នុងវិស័យព្រៃឈើ និងការត្រួត ពិនិត្យ ដោយមានការចូលរួម និងប្រព័ន្ធវាយតម្លៃ។

ការពង្រីកទំនាក់ទំនងរបស់ RECOFTC ទៅក្នុងប្រទេសគោលដៅទាំង ០៨ ដែលរួមមាន ប្រទេសកម្ពុជា ចិន ឥណ្ឌូនេស៊ី ឡាវ មីយ៉ាន់ម៉ា នេប៉ាល់ ថៃ និងវៀតណាម នៅតែបន្តជាមូលដ្ឋានគ្រឹះសំខាន់ក្នុងការសម្រេចបានលទ្ធផលជាក់ស្តែង។ យុទ្ធសាស្ត្រអនុវត្តទាំងបួនដែលរួមមាន ការបណ្តុះបណ្តាល និងបណ្តាញសិក្សារៀនសូត្រ ការស្រាវជ្រាវ ការទំនាក់ទំនង និងការអនុវត្តន៍សាកល្បង រួមចំណែកក្នុងការសម្រេចបានលទ្ធផលជាយុទ្ធសាស្ត្ររបស់ RECOFTC។

សៀវភៅផែនការយុទ្ធសាស្ត្រនេះអាចទាញយកបានពីគេហទំព័ររបស់ RECOFTC: www.recoftc.org














ការតាំងពិពណ៌បានបង្ហាញនូវផលិតផល និងសកម្មភាពផ្សេងៗរបស់ក្រុមសហគ្រាសសហគមន៍ក្នុងរយៈពេល ០២ ថ្ងៃក្នុងវេទិកានេះ។ ដៃគូសហការណ៍រៀបចំរៀបចំវេទិកានេះ ក៏បានដាក់តាំងបង្ហាញនូវស្នាដៃរបស់គេរៀងៗខ្លួនផងដែរ។ សហគ្រាសសហគមន៍ដែលបានដាក់តាំងផលិតផលរបស់ពួកគេនៅសាលតាំងពិពណ៌ផលិតផលរួមមាន៖

- Baan Maab Lao Cha-oun Community Forest
- Biodiversity-Based Economy Development Office ( BEDO )
- Community enterprise group of organic coffee and forest conservation Baan Khun Lao
- Non-Timber Forest Products Exchanged Programme ( NTFP-EP )


Many Lessons Learned

# ការយល់ឃើញផ្សេងៗ ចំពោះសហគមន៍ព្រៃឈើ

គេបានទទួលស្គាល់ពីវឌ្ឍនភាពរបស់សហគមន៍ព្រៃឈើ ប៉ុន្តែដើម្បីជម្រុញសហគមន៍ព្រៃឈើឱ្យកាន់តែប្រសើរឡើងថែមទៀត ចាំបាច់ត្រូវពិចារណាទៅលើទិដ្ឋភាពថ្មីមួយចំនួនទៀត ព្រមទាំងផ្តោតការយកចិត្តទុកដាក់ទៅលើទម្រង់នៃការផ្លាស់ប្តូរ ដែលជាមូលដ្ឋានក្នុងការពិចារណា និងលើកយកមកពិភាក្សានៅពេលអនាគត។ បញ្ហាប្រឈមកើតមានឡើងជានិច្ច ប៉ុន្តែបញ្ហាទាំងនេះក៏ផ្តល់ជាឱកាសសម្រាប់ពង្រឹងសហគមន៍ព្រៃឈើឱ្យកាន់តែប្រសើរឡើងផងដែរ ដូចជាតាមរយៈកិច្ចសហការណ៍ និងការភ្ជាប់ខ្លួនទៅកាន់វិស័យផ្សេងទៀតទៅលើការប្រែប្រួលអាកាសធាតុ ការយកចិត្តទុកដាក់ជម្រុញឱ្យសហគមន៍ព្រៃឈើផ្តោតទៅលើសហគ្រាសពាណិជ្ជកម្ម។ បញ្ហានេះត្រូវបានវាគ្មិនទាំងបីរូបលើកឡើងជាបញ្ហាគន្លឹះសំខាន់។




លោកបណ្ឌិត Don Gilmour សមាជិកកិត្តិយសរបស់ RECOFTC បានលើកឡើងនូវបញ្ហាប្រឈមនានា រវាងព្រៃឈើ និងទឹកដែលពាក់ព័ន្ធដល់គោលនយោបាយសហគមន៍ព្រៃឈើ និងការអនុវត្ត។ លោកបានលើកឡើងថា៖ "ករណីខ្លះ មិនដូចគ្នាទេនូវអ្វីដែលគេនិយាយតៗគ្នាមក និងអ្វីដែលវិទ្យាសាស្ត្របានរកឃើញរវាងទំនាក់ទំនងទឹក និងព្រៃឈើ។

លោកបណ្ឌិត Bhishma Subedi នាយកប្រតិបត្តិ Asia Network for Sustainable Agriculture and Bioresources (ANSAB) បានលើកឡើងថាសហគមន៍ព្រៃឈើមានសក្តានុពលខ្លាំង ជួយដល់វិស័យសេដ្ឋកិច្ច តាមរយៈការអភិវឌ្ឍសហគ្រាស និងតាមរយៈការលើកកម្ពស់ការប្រើប្រាស់ និងការគ្រប់គ្រងផលិតកម្មព្រៃឈើ។ "នៅក្នុងតំបន់មួយចំនួន ព្រៃឈើសហគមន៍មានការដុះលូតលាស់ល្អនិង លើសពីតម្រូវការប្រើប្រាស់ នៅពេលដែលការគ្រប់គ្រង និងការប្រើប្រាស់ព្រៃឈើប្រព្រឹត្តទៅដោយនិរន្តរភាព។ កត្តានេះតម្រូវឱ្យមានបំលាស់ប្តូរពីការគ្រប់គ្រងសហគមន៍ព្រៃឈើតាមបែបប្រពៃណីឱ្យទៅជាសហគ្រាសសហគមន៍ព្រៃឈើវិញដើម្បីបន្តនិរន្តរភាព"។




លោក Sugeng Marsudiarto អគ្គនាយករងនៃអគ្គនាយកដ្ឋានអភិវឌ្ឍន៍ព្រៃឈើសង្គម នៃក្រសួងគ្រប់គ្រងព្រៃឈើប្រទេសឥណ្ឌូនេស៊ីបានចែករំលែកព័ត៌មានទាក់ទងទៅនឹងក្របខណ្ឌការងារពហុវិស័យរបស់អាស៊ានស្តីពីការប្រែប្រួលអាកាសធាតុ (AFCC) ដោយលោកបានមានប្រសាសន៍ថា៖ "ប្រជាជននៅតំបន់អាស៊ីអាគ្នេយ៍រស់នៅ ប្រមូលផ្តុំគ្នាតាមបណ្តោយឆ្នេរសមុទ្រ និងពឹងផ្អែកលើកសិកម្ម និងវិស័យព្រៃឈើជាហេតុធ្វើឱ្យតំបន់នេះ ក្លាយជាតំបន់ងាយរងគ្រោះបំផុតលំដាប់ទី ៣ នៅក្នុងពិភពលោក ពីការប្រែប្រួលអាកាសធាតុ។ ការប្រែប្រួលអាកាសធាតុគឺជាបញ្ហាអន្តរវិស័យ ដែលទាមទារឱ្យមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់"។ លោកក៏បានលើកឡើងដែរថា អាស៊ានបាននឹងកំពុងអនុវត្តន៍ជាបណ្តើរៗ នូវក្របខណ្ឌការងារពហុវិស័យរបស់ខ្លួនស្តីពីការប្រែប្រួលអាកាសធាតុដែលស្តីអំពី៖ កសិកម្ម និងព្រៃឈើឆ្ពោះទៅរកសន្តិសុខស្បៀងអាហារ។

សម្រាប់ព័ត៌បន្ថែម សូមអានឯកសារដែលចេញផ្សាយដោយ RECOFTC
http://www.recoftc.org/site/resources/Seeing-community-forestry-differently.php



# ផែនការសកម្មភាពប្រទេសរួមគ្នាដើម្បីពង្រឹងសហគមន៍ព្រៃឈើ

អ្នកចូលរួមបានបំបែកគ្នាជាក្រុមទៅតាមប្រទេសរៀងៗខ្លួន ដើម្បីធ្វើការពិភាក្សាទៅលើផ្នែកសំខាន់ៗនៃផែនការសកម្មភាពប្រទេសរួមគ្នា (ភាគីពាក់ព័ន្ធពហុវិស័យ) ដែលលើកឡើងពីតម្រូវការចាំបាច់ក្នុងការពង្រឹងសហគមន៍ព្រៃឈើដូចជា៖ ការកំណត់ភាគីពាក់ព័ន្ធ ការកំណត់សកម្មភាពជាអាទិភាព របស់ភាគីពាក់ព័ន្ធផ្សេងៗ និងលទ្ធផលរំពឹងទុក។ ដើម្បីបង្កើតជាផែនការសកម្មភាពនេះក្រុមប្រទេសនីមួយៗបានពិភាក្សាគ្នាទៅលើសំនួរជាច្រើន ដែលផ្តោតទៅលើស្ថានភាពជាក់ស្តែងរបស់ប្រទេសរៀងៗខ្លួន។

នៅចុងបញ្ចប់នៃវេទិកានេះ អ្នកចូលរួមបានប្រមូលផ្តុំ ទៅតាមប្រទេសនីមួយៗដើម្បីធ្វើបទបង្ហាញអំពីផែនការសកម្មភាពប្រទេសរួមគ្នា ដើម្បីចូលរួមក្នុងការពង្រឹងសហគមន៍ព្រៃឈើ។ រាល់អនុសាសន៍ទាំងអស់នឹងប្រើជាមូលដ្ឋានដើម្បីពិភាក្សាបន្តក្នុងវេទិកាថ្នាក់ជាតិដែលនឹងប្រព្រឹត្តទៅនៅដើមឆ្នាំ ២០១៤ ក្នុងប្រទេសទាំង ៦ ដូចជាប្រទេសកម្ពុជា ឥណ្ឌូនេស៊ី ឡាវ មីយ៉ាន់ម៉ា ថៃ និងវៀតណាម។


7



# ប្រទេសកម្ពុជា

សហគមន៍ព្រៃឈើនៅក្នុងប្រទេសកម្ពុជាមានវឌ្ឍនភាពគួរឱ្យកត់សម្គាល់នៅកំលុងពីរទសវត្សរ៍ចុងក្រោយនេះ តាមរយៈការបង្កើន ឱ្យមានគោលនយោបាយច្បាស់លាស់ លិខិតបទដ្ឋានគតិយុត្តនានា និងការពង្រឹងស្ថាប័នមូលដ្ឋាន។ រាជរដ្ឋាភិបាលកម្ពុជាបានប្តេជ្ញាចិត្ត ក្នុងការបង្កើនព្រៃសហគមន៍ឱ្យបាន ២ លានហិកតានៅត្រឹមឆ្នាំ ២០២៩។ គិតមកត្រឹមឆ្នាំ ២០១៣ មានសហគមន៍ព្រៃឈើសរុបចំនួន ៤៥៧ កន្លែងដែលគ្របដណ្តប់លើផ្ទៃដីព្រៃឈើជាង ៤០០.០០០ ហិកតា។ ការបង្កើនល្បឿននៃដំណើរការរៀបចំផែនការគ្រប់គ្រងព្រៃសហគមន៍ មានសារៈសំខាន់ក្នុងការសម្រេចបានជោគជ័យរយៈពេលវែងចំពោះសហគមន៍ព្រៃឈើនៅក្នុងប្រទេសកម្ពុជា។ មកដល់ពេលនេះមានផែនការគ្រប់គ្រងព្រៃសហគមន៍មួយប៉ុណ្ណោះដែលត្រូវបានអនុម័ត និងផែនការគ្រប់គ្រងព្រៃសហគមន៍ចំនួន ២០ ផ្សេងទៀតកំពុងរង់ចាំការអនុម័ត។ ការចាត់អាទិភាពទៅលើគោលការណ៍ណែនាំ និងការអនុវត្តផែនការគ្រប់គ្រងសហគមន៍ព្រៃឈើដែលបានអនុម័តទទួលស្គាល់ នឹងជម្រុញឱ្យមានការផ្លាស់ប្តូរសំខាន់មួយដែលនាំទៅដល់ការបង្កើនធនធានផលិតផល និងការអភិវឌ្ឍសហគ្រាស ។ ដូចនេះ ការអនុម័តផែនការគ្រប់គ្រង និងបើកផ្លូវឱ្យមានគ្រប់គ្រងសកម្ម និងការប្រើប្រាស់ធនធានប្រកបដោយនិរន្តរភាព។




ការប្តេជ្ញាចិត្តសម្រាប់រយៈពេលបីឆ្នាំខាងមុខ៖

- ការពិនិត្យឡើងវិញ និងធ្វើការសម្រេចចុងក្រោយទៅលើសៀវភៅណែនាំស្តីពីការរៀបចំផែនការគ្រប់គ្រងព្រៃសហគមន៍
- បង្កើតសហគមន៍ព្រៃឈើ និងធានាដល់ការទទួស្គាល់សហគមន៍ព្រៃឈើពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បន្តធ្វើការសាកល្បង និងបង្ហាញពីភាពជោគជ័យនៃការគ្រប់គ្រងសហគមន៍ព្រៃឈើ។

## តារាងស្វែងយល់ពីស្ថានភាពសហគមន៍

អ្នកចូលរួមក្នុងវេទិកាដែលមកពីប្រទេសកម្ពុជាបានចូលរួមពិភាក្សាដកស្រង់នូវចំនុចសំខាន់ៗដូចខាងក្រោម៖

| | |
|---|---|
| 1. ទិន្នន័យដែលបង្ហាញពីស្ថានភាពបច្ចុប្បន្ននៃសហគមន៍ព្រៃឈើ | • វិស័យជលផល៖ សហគមន៍នេសាទគ្របដណ្តប់ផ្ទៃទឹកសរុបទំហំជាង ៧០០. ០០០ ហិកតា ។ មានសហគមន៍នេសាទជាង ៥០០ ដែលក្នុងនោះ សហគមន៍ ២០០ បានចុះបញ្ជីនៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។ ផែនការរបស់សហគមន៍នេសាទភាគច្រើនត្រូវបានរៀបចំ និងអនុម័ត ។<br>• មកដល់ពេលនេះមានសហគមន៍តំបន់ការពារធម្មជាតិចំនួន ១២០ គ្របដណ្តប់ទៅលើផ្ទៃដី ១៦៤.៤៨០ ហិកតា មានផែនការគ្រប់គ្រង១០ (ផែនការ ៥ ត្រូវបានអនុម័ត)។<br>• រដ្ឋាភិបាលបានប្តេជ្ញាចិត្តក្នុងការបង្កើនព្រៃសហគមន៍ឱ្យបាន ២ លានហិកតាត្រឹមឆ្នាំ ២០២៩ ។ មកដល់ពេលនេះមានសហគមន៍ព្រៃឈើចំនួន ៤៥៧ ត្រូវបានបង្កើតឡើង ដែលគ្របដណ្តប់លើផ្ទៃដីព្រៃឈើជាង ៤០០.០០០ ហិកតា ។ ក្នុងនោះមានសហគមន៍ចំនួន ៣៤៥ បានទទួលកិច្ចព្រមព្រៀងពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងផែនការគ្រប់គ្រងសហគមន៍ព្រៃឈើ ១ បានទទួលការអនុម័ត និងផែនការគ្រប់គ្រងសហគមន៍ព្រៃឈើចំនួន ២០ ផ្សេងទៀតស្ថិតនៅក្នុសេចក្តីព្រាងនៅឡើយ។ |
| 2. តើសំនួរអ្វីខ្លះដែលត្រូវចោទឡើងដើម្បីជម្រុញសហគមន៍ព្រៃឈើឱ្យឆ្ពោះទៅមុខ ? | • តើមានឧបសគ្គផ្នែកច្បាប់អ្វីខ្លះ ដែលរាំងស្ទះដល់ការអនុវត្តន៍សហគមន៍ព្រៃឈើ ? តើយើងមានដំណោះស្រាយដូចម្តេចចំពោះបញ្ហាទាំងនេះ ?<br>• តើគេត្រូវគាំទ្រ ( ទាំងថវិការ និងបច្ចេកទេស ) និងធានានិរន្តរភាពនៃការអនុវត្តន៍ផែនការគ្រប់គ្រងសហគមន៍ព្រៃឈើ សហគមន៍នេសាទ និងសហគមន៍តំបន់ការពារធម្មជាតិតាមវិធីណា ?<br>• តើត្រូវកែលំអរ និងលើកកម្ពស់ បណ្តាញសហគមន៍ព្រៃឈើ បណ្តាញសហគមន៍តំបន់ការពារធម្មជាតិ បណ្តាញសហគមន៍នេសាទ បណ្តាញគណកម្មការសម្របសម្រួលកម្មវិធីព្រៃឈើថ្នាក់មូលដ្ឋាន និងថ្នាក់ខេត្ត តាមវិធីណា ? |
| 3. តើអ្នកចង់ឃើញការផ្លាស់ប្តូរអ្វីខ្លះក្នុងតួនាទីរបស់ភាគីពាក់ព័ន្ធ ? | • អាជ្ញាធរដែនដី អនុវត្តគោលនយោបាយជាតិ<br>• សហគមន៍មូលដ្ឋានមានអំណាចក្នុងការអនុវត្តនូវអ្វីដែលច្បាប់បានផ្តល់ឱ្យ<br>• តើយើងធ្វើដូចម្តេច ដើម្បីឱ្យស្ថាប័នព័ត៌មាន បង្កើនការផ្សព្វផ្សាយពីសហគមន៍ព្រៃឈើ ?<br>• តើយើងធ្វើដូចម្តេចដើម្បីឱ្យវិស័យឯកជន ចូលរួមជាមួយសហគមន៍មូលដ្ឋានក្នុងកំលុងពេលដំណើរការអភិវឌ្ឍសហគមន៍ ? |
| 4. តើបទបង្ហាញទាំងអស់ដែលបានលើកឡើងក្នុងវេទិការនេះបានបង្ហាញអ្វីខ្លះដល់អ្នក ? | • ព្រៃឈើ និងទឹក: ត្រូវធ្វើការតាមដានបន្ថែមទៀតទៅលើទីតាំងជាក់លាក់<br>• សហគ្រាសសហគមន៍ព្រៃឈើ: គម្រូបែបប្រពៃណីបានចាក់ឫសគល់ក្នុងប្រទេសកម្ពុជា ហើយការអនុវត្តន៍គំរូថ្មីនៅមានកម្រិតនៅឡើយ ។ ត្រូវពិនិត្យ និងកែសម្រួលឡើងវិញនូវគោលការណ៍សហគមន៍ព្រៃឈើ និងសហគមន៍តំបន់ការពារធម្មជាតិ ដើម្បីលើកកម្ពស់ដល់ការអនុវត្តគំរូថ្មី និងជាពិសេសការទំនាក់ទំនងជាមួយវិស័យឯកជន ។<br>• ការប្រែប្រួលអាកាសធាតុ: ត្រូវបញ្ចូលបញ្ហានេះទៅក្នុង សហគមន៍តំបន់ការពារធម្មជាតិ (ក្រសួងបរិស្ថាន) សហគមន៍នេសាទ (ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ) ក្នុងបណ្តាញព្រៃឈើអាស៊ាន (ASFN) ដើម្បីធ្វើការពិចារណា។ តើគេត្រូវភ្ជាប់គោលនយោបាយការប្រែប្រួលអាកាសធាតុ/ផែនការសកម្មភាព ទៅនឹងកម្មវិធីព្រៃឈើជាតិដែលមានស្រាប់តាមវិធីណា ? |
| 5. រយៈបីឆ្នាំបន្ទាប | • ផ្តល់អំណាចដល់សហគមន៍មូលដ្ឋាន<br>• បង្កើនធនធាន<br>• អភិវឌ្ឍន៍សហគ្រាស<br>• វេទិកាពិភាក្សា |

## តារាងបង្ហាញពីការផ្លាស់ប្តូរក្នុងសហគមន៍ព្រៃឈើ

អ្នកចូលរួមមកពីប្រទេសកម្ពុជាបានដកស្រង់ខ្លឹមសារពីកិច្ចពិភាក្សាក្នុងក្រុមរបស់ខ្លួន និងយុទ្ធសាស្ត្រជម្រុញសហគមន៍ព្រៃឈើឱ្យកាន់តែប្រសើរឡើងដូចតទៅ៖

**តើអ្នកណាខ្លះនឹងជួយអ្នក?**

- ដៃគូអភិវឌ្ឍ
- រដ្ឋបាលព្រៃឈើ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- អគ្គនាយកដ្ឋាន រដ្ឋបាលការពារ និងអភិរក្សធម្មជាតិ នៃក្រសួងបរិស្ថាន
- អង្គការនានា

**តើអ្នកនឹងធ្វើអ្វីខ្លះ?**

- អនុវត្តគម្រោងសាកល្បង
- ត្រួតពិនិត្យឡើងវិញ និងសម្រេចទៅលើសៀវភៅផែនការគ្រប់គ្រងសហគមន៍ព្រៃឈើ
- ត្រួតពិនិត្យឡើងវិញ និងសម្រេចទៅលើគោលការណ៍ណែនាំស្តីពីសហគមន៍តំបន់ការពារធម្មជាតិ
- ចុះបញ្ជីសហគមន៍នេសាទនៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ផ្តល់វគ្គបណ្តុះបណ្តាល និងរៀបចំកិច្ចពិភាក្សាពហុភាគី

**តើអ្នកនឹងជួយឱ្យមានការផ្លាស់ប្តូរយ៉ាងដូចម្តេច?**

- ចងក្រងឯកសារ និងចែករំលែកដើម្បីឱ្យមានការផ្លាស់ប្តូរ

**តើអ្នកនឹងធ្វើទំនាក់ទំនងយ៉ាងដូចម្តេចខ្លះ?**

- ប្រព័ន្ធផ្សព្វផ្សាយ
- ការចងក្រងបណ្តាញ
- សិក្ខាសាលា
- កិច្ចប្រជុំ
- ការនិយាយគ្នាដោយផ្ទាល់

**តើអ្នកធ្វើឱ្យគេស្គាល់នឹងចែកចាយព័ត៌មានតាមវិធីណា?**

- ការចងក្រងបណ្តាញ
- ការប្រើប្រាស់គេហទំព័រដែលមានស្រាប់
- បណ្តាញសង្គម
- កិច្ចពិភាក្សាពហុភាគី

**តើអ្នកណាខ្លះនឹងអាចជួយអ្នកបាន?**

- បណ្តាញសហគមន៍នេសាទ សហគមន៍ព្រៃឈើ និងសហគមន៍តំបន់ការពារធម្មជាតិ
- រដ្ឋបាលព្រៃឈើ អគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ និងរដ្ឋបាលជលផល
- អាជ្ញាធរមូលដ្ឋាន
- អង្គការជាតិ
- ក្រុមការងារបច្ចេកទេស
- ក្រុមការងារកម្មវិធីសហគមន៍ព្រៃឈើជាតិ

**តើអ្នកនឹងចូលរួមចំណែកអ្វីខ្លះ?**

- ពេលវេលា
- ជំនាញឯកទេស
- ឯកសារ

**តើអ្នកនឹងទទួលបានអ្វីខ្លះមកវិញ?**

- ផលប្រយោជន៍ដល់ការស្វែងរកការគាំទ្រ
- ផ្តល់មេរៀនថ្មីៗសម្រាប់កាពង្រឹងសហគមន៍នេសាទ សហគមន៍ព្រៃឈើ និងសហគមន៍តំបន់ការពារធម្មជាតិ
- ការគាំទ្រគោលនយោបាយកាន់តែប្រសើរ
- គោលការណ៍ណែនាំផែនការគ្រប់គ្រងសហគមន៍ព្រៃឈើ
- គោលការណ៍ណែនាំសហគមន៍តំបន់ការពារធម្មជាតិ
- លក្ខន្តិកៈសហគមន៍នេសាទ
- ការប្តេជ្ញាចិត្តក្នុងការបរិច្ចាកពេលវេលារបស់បុគ្គលិកជំនាញ និងជំនួយថវិកា
- បណ្តាញសហគមន៍ព្រៃឈើរួមចំណែកដល់ការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព
- ចំនួនផែនការគ្រប់គ្រងសហគមន៍ព្រៃឈើត្រូវបានអនុម័ត និងដាក់ឱ្យប្រើប្រាស់



5 Facts to describe current status of CF
CF
Community



# ប្រទេសចិន

ការបញ្ជ្រាបសហគមន៍ព្រៃឈើទៅក្នុងផែនការអភិវឌ្ឍជាតិគឺជារបៀបវារៈដ៏សំខាន់មួយនៅក្នុងប្រទេសចិន។ ការពង្រឹងទំនាក់ទំនងបណ្តាញក្នុងប្រទេសចិន និងបណ្តាញប្រទេសផ្សេងទៀតក្នុងតំបន់មានសារៈសំខាន់ខ្លាំងណាស់ក្នុងការបង្កើតកិច្ចសហប្រតិបត្តិការណ៍ ការរៀនសូត្រពីគ្នាទៅវិញទៅមក ព្រមទាំងការធ្វើពាណិជ្ជកម្មផលិតផល និងសេវាកម្មរបស់សហគមន៍ព្រៃឈើដែលជាយុទ្ធសាស្រ្តស្នូលសម្រាប់សហគមន៍ព្រៃឈើ។ ការលើកកម្ពស់ទំនាក់ទំនង រវាងភាគីពាក់ព័ន្ធ គឺជាតម្រូវការចាំបាច់របស់សហគមន៍ព្រៃឈើ ហើយការផ្តោតទៅលើគុណតម្លៃនៃគំរូជាក់លាក់ណាមួយរបស់សហគមន៍ព្រៃឈើ ក្នុងការគ្រប់គ្រងព្រៃឈើសមូហភាព នឹងបង្ហាញឱ្យឃើញនូវភាពចាំបាច់នេះ។ កត្តានេះ អាចសម្រេចទៅបានតាមរយៈការចងក្រងឯកសារ និងចែកចាយទៅវិញទៅមកនូវឯកសារស្តីពីការអនុវត្តគំរូ នៅជុំវិញបញ្ហានេះ។

ការប្តេជ្ញាចិត្តសម្រាប់រយៈបីឆ្នាំខាងមុខ៖

- ចងក្រងឯកសារស្តីការអនុវត្តន៍គំរូ ( best practice ) តាមរយៈគំរូ ដែលមានស្រាប់ និងចែកចាយឯកសារទាំងនេះទៅកាន់អ្នកបង្កើតគោលនយោបាយសំខាន់ៗ
- ផ្តល់វគ្គបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងជម្លោះ និងការគ្រប់គ្រងធនធានធម្មជាតិដោយនិរន្តរភាពនៅកម្រិតមូលដ្ឋាន
- ធ្វើទំនាក់ទំនងជាមួយស្ថាប័នសារព័ត៌មាន ដើម្បីផ្សព្វផ្សាយបន្តពីការលើកកម្ពស់ការយល់ដឹងស្តីពីគំរូល្អរបស់សហគមន៍ព្រៃឈើ និងកត្តានានាដែលជម្រុញទៅរកភាពជោគជ័យ។




# ប្រទេសឥណ្ឌូនេស៊ី

សហគមន៍ព្រៃឈើនៅក្នុងប្រទេសឥណ្ឌូនេស៊ីមានច្រើនទម្រង់ ហើយត្រូវបានរដ្ឋាភិបាលទទួលស្គាល់ និងដាក់បញ្ចូលរួចរាល់ទៅក្នុងផែនការអភិវឌ្ឍជាតិ (រយៈពេលមធ្យម)។ គោលដៅក្នុងការពង្រីកតំបន់សហគមន៍ព្រៃឈើសម្រេចបានជាបណ្តើរៗ ក្នុងជំហានយឺតៗ។ គេត្រូវផ្តោតការយកចិត្តទុកដាក់បន្ថែមទៀត ដើម្បីផ្លាស់ប្តូរសហគមន៍ព្រៃឈើបែបប្រពៃណី ទៅជាលក្ខណៈពាណិជ្ជកម្ម នេងទាញយកផលប្រយោជន៍សេដ្ឋកិច្ចពិតប្រាកដពីព្រៃឈើ។ រដ្ឋាភិបាលបានដាក់ចេញគោលដៅសម្រេចឱ្យបានសហគមន៍ព្រៃឈើចំនួន ២,៥ លានហិកតា ដែលមកដល់បច្ចុប្បន្ននេះសហគមន៍ព្រៃឈើដែលបង្កើតឡើងគ្របដណ្តប់លើ ផ្ទៃដីសរុបចំនួន ៣៦០.០០០ ហិកតា។ ថ្មីៗនេះរដ្ឋាភិបាលទទួលស្គាល់សិទ្ធិរបស់ជនជាតិដើមភាគតិចក្នុងការគ្រប់គ្រងព្រៃឈើ ប៉ុន្តែនៅមិនទាន់មានច្បាប់អនុវត្តច្បាស់លាស់នៅឡើយ។ យុទ្ធសាស្ត្រក្នុងការពង្រីកតំបន់សហគមន៍ព្រៃឈើ នៅក្នុងកម្រិតតំបន់ទេសភាពត្រូវបានកំណត់ជាអាទិភាពដោយការលើកកម្ពស់លើការសម្របសម្រួល រវាងរដ្ឋាភិបាលថ្នាក់កណ្តាល និងថ្នាក់មូលដ្ឋាន។ ការធានាការពង្រីកសហគមន៍ព្រៃឈើ ដែលត្រូវបានបញ្ជ្រាបទៅក្នុងផែនការលម្អិត នៅកម្រិតមូលដ្ឋានគឺជាការផ្លាស់ប្តូរគន្លឹះមួយ ដែលត្រូវពង្រឹងបន្ថែមទៀតនៅពេលបីឆ្នាំបន្ទាប់។



ការប្ដេជ្ញាចិត្តសម្រាប់ ៣ឆ្នាំបន្ទាប់៖

- រដ្ឋាភិបាលទទួលស្គាល់ព្រៃរបស់ជនជាតិដើមភាគតិចចំនួន ២ លានហិកតា
- ពង្រីកផ្ទៃដីព្រៃដែលគ្រប់គ្រងដោយសហគមន៍ឱ្យបាន ៥ លានហិកតា
- ផលិតផលសំខាន់ៗបានមកពីព្រៃសហគមន៍ចំនួន ៥ ប្រភេទត្រូវបានធ្វើពាណិជ្ជកម្ម
- សម្រេចឱ្យបាន ៣០% នៃចំនួនក្រុមអ្នកប្រើប្រាស់ព្រៃឈើ ។

ការប្ដេជ្ញាចិត្តខាងលើនេះអាចសម្រេចទៅបានអាស្រ័យលើយុទ្ធសាស្ត្រដូចខាងក្រោមនេះ៖

- បញ្ចូលកម្មវិធីពង្រីកសហគមន៍ព្រៃឈើទៅក្នុងផែនការអភិវឌ្ឍរយៈពេលមធ្យម និង ផែនការលម្អិតរបស់រដ្ឋាភិបាល ថ្នាក់មូលដ្ឋាន
- ពង្រឹងការរៀបចំថវិកា និងការរៀបចំផែនការសម្រាប់ការអភិវឌ្ឍសហគមន៍ព្រៃឈើ
- ពិនិត្យមើលឡើងវិញ និងពង្រឹងលក្ខខន្តិកសម្រាប់ការផ្ដល់សិទ្ធិជូនតំបន់សហគមន៍ព្រៃឈើ
- ផ្ដោតការយកចិត្តទុកដាក់ទៅលើទំនាក់ទំនងជាមួយវិស័យឯកជន ដើម្បីអភិវឌ្ឍន៍សហគ្រាសសហគមន៍ព្រៃឈើ។




# ប្រទេសឡាវ

គោលនយោបាយ និងក្របខ័ណ្ឌស្ថាប័នសម្រាប់សហគមន៍ព្រៃឈើក្នុងប្រទេសឡាវត្រូវបានដាក់ឱ្យប្រើប្រាស់ទាំងក្នុងផ្នែករដ្ឋបាលព្រៃឈើភូមិ នៅកម្រិតថ្នាក់មូលដ្ឋាន និងថ្នាក់កណ្តាលផងដែរ។ គម្រោងសាកល្បងបាននាំទៅរកការបង្កើតឧបករណ៍ និងគោលការណ៍ណែនាំសម្រាប់ការអនុវត្តន៍ព្រៃឈើភូមិ និងការបែងចែកដី។ ការយល់ដឹងរបស់មូលដ្ឋាន ចំពោះផលប្រយោជន៍របស់ព្រៃឈើភូមិត្រូវតែពង្រឹងបន្ថែមទៀតជាចំបាច់។




ដើម្បីបង្កើនល្បឿនការអនុវត្តសហគមន៍ព្រៃឈើ និងទទួលបានបទពិសោធន៍ ស្តីពីការងារគម្រូបន្ថែមទៀតនៅពេលដែលមានការប្តេជ្ញាចិត្តនាពេល ៣ ឆ្នាំខាងមុខគេត្រូវ៖

- គាំទ្រ និងពង្រឹងអនុក្រុមការងារសហគមន៍ព្រៃឈើ ដើម្បីចម្រាញ់យកការងារគំរូ និងផ្តល់ប្រឹក្សាយោបល់ក្នុងការរៀបចំគោលនយោបាយ ទៅកាន់ភាគីពាក់ព័ន្ធសំខាន់ៗ
- បង្កើនចំនួនគ្រូបង្គោល ដែលមានជំនាញទៅខាងសហគមន៍ព្រៃឈើ តាមរយៈការបណ្តុះបណ្តាលដោយផ្តោតទៅលើគំរូព្រៃឈើភូមិ
- បង្កើតគំរូការដាំកូនឈើសាកល្បងដោយផ្អែកលើ forest certification ការចងក្រងមេរៀន ការងារគំរូសម្រាប់ចែកចាយទៅកាន់ភាគីពាក់ព័ន្ធផ្សេងៗ ។




# ប្រទេសមីយ៉ាន់ម៉ា

រដ្ឋាភិបាលរបស់មីយ៉ាន់ម៉ា បានដាក់ចុះគោលដៅសម្រេចឱ្យបាន ២,២៧ លានអារ ក្នុងការបង្កើតសហគមន៍ព្រៃឈើ ទោះបីជាមិនទាន់មានភាពប្រាកដប្រជាក្នុងការផ្តល់ថវិកាជាតិគាំទ្រការអនុវត្តកម្មវិធីនេះក៏ដោយ។ មកដល់ពេលបច្ចុប្បន្ន មានដីសហគមន៍ព្រៃឈើចំនួន ១១០.០០០ អារ និងមានក្រុមអាស្រ័យផលព្រៃឈើចំនួន ៧៤០ក្រុម។ គេត្រូវការយុទ្ធសាស្ត្រក្នុងការពង្រីកការអនុវត្តន៍ ដើម្បីសម្រេចឱ្យបានគោលដៅដែលបានកំណត់នេះ។ ផ្ទៃដីសហគមន៍ព្រៃឈើដែលបានបង្កើតឡើងរួចហើយ មួយចំនួនត្រូវបានគេអះអាងជាន់គ្នាជាមួយនឹងដីសម្បទានសេដ្ឋកិច្ចដែលបង្កឱ្យមានជម្លោះ។ សិទ្ធកាន់កាប់ដីសហគមន៍ព្រៃឈើត្រូវចំបាច់ត្រូវពង្រឹងបន្ថែមទៀតតាមរយៈការផ្លាស់ប្តូរក្របខណ្ឌគតិយុត្តព្រោះសិទ្ធកាន់កាប់ដីព្រៃឈើសហគមន៍ដែលមានរយៈពេល ៣០ ឆ្នាំបច្ចុប្បន្នមិនទាន់មានការគាំទ្រផ្នែកផ្លូវច្បាប់រឹងមាំនៅឡើយ។




ប្រទេសមីយ៉ាន់ម៉ាយល់ឃើញថា ដើម្បីពង្រីកតំបន់សហគមន៍ព្រៃឈើទៅបាន ចំបាច់ត្រូវមានក្របខណ្ឌគតិយុត្តរឹងមាំ ដែលគាំទ្រដល់សិទ្ធិកាន់កាប់។ ដូចខាងក្រោមនេះពួកគេបានធ្វើការប្តេជ្ញាចិត្តសម្រាប់រយៈពេល ៣ ឆ្នាំខាងមុខដូចខាងក្រោមនេះ៖

- ធ្វើការស្រាវជ្រាវដោយផ្អែកលើភស្តុតាងដែលមានស្រាប់ ដើម្បីស្វែងរកការគាំទ្រផ្នែកគោលនយោបាយ និង ក្របខណ្ឌគតិយុត្ត
- ពង្រឹង និងសម្របសម្រួលក្រុមការងារសហគមន៍ព្រៃឈើថ្នាក់ជាតិ
- បង្កើតសហគមន៍ព្រៃឈើគំរូ  តាមរយៈការកសាងសមត្ថភាព និងការគៀងគររកប្រភពធនធាន
- បង្កើនកម្រិតជីវភាពរបស់សហគមន៍មូលដ្ឋាន  តាមរយៈការអនុវត្តន៍សកម្មភាពនានាក្នុងសហគមន៍ព្រៃឈើ។



# ប្រទេសនេប៉ាល់

ដំណើរការបង្កើតសហគមន៍ព្រៃឈើនៅក្នុងប្រទេសនេប៉ាល់ បានប្រព្រឹត្តទៅយ៉ាងរលូនដែលបច្ចុប្បន្ននេះមានព្រៃឈើរហូតដល់ ១,៧០ លានហិកតា ស្ថិតនៅក្រោមការគ្រប់គ្រង និងចាត់ចែងរបស់ក្រុមអ្នកប្រើប្រាស់ព្រៃឈើចំនួន ១៨.១៣៣ ក្រុម។ ចំណូលដែលបានមកពីសហគមន៍ព្រៃឈើត្រូវបានគេប៉ាន់ប្រមាណថាមានប្រហែល ៥០ លានដុល្លារ ក្នុងមួយឆ្នាំនាពេលបច្ចុប្បន្ននេះ។ បើទោះបីជាកន្លងមក សហគមន៍ព្រៃឈើបានបំពេញការងារប្រកបដោយជោគជ័យក្នុងកិច្ចខិតខំការពារក៏ដោយ ក៏គេត្រូវពង្រឹងការគ្រប់គ្រងព្រៃឈើបន្ថែមទៀតដើម្បីបង្កើនលទ្ធភាពផលិតផលព្រៃឈើ ហើយផ្តល់ផលប្រយោជន៍កាន់តែប្រសើរឡើងដល់ប្រជាជនមូលដ្ឋាន ដែលនេះនឹងញ៉ាំងឱ្យពួកគេខិតខំបន្ត ការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាពនៅពេលអនាគត និងដើម្បីការពារផលប្រយោជន៍ទាំងរដ្ឋាភិបាល និងក្រុមរបស់ខ្លួន(ក្រុមអ្នកប្រើប្រាស់ព្រៃឈើ)។

តម្រូវការនាពេលអនាគត គឺការបង្កើនការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព និងការវិនិយោគពីសំណាក់វិស័យឯកជនក្នុងសហគ្រាសសហគមន៍ព្រៃឈើ ព្រមទាំងការគាំទ្របច្ចេកទេសដល់ក្រុមអ្នកប្រើប្រាស់ព្រៃឈើ ដើម្បីពិនិត្យឡើងវិញនូវផែនការគ្រប់គ្រងការប្រតិបត្តិ។ ការពង្រឹងអភិបាលកិច្ចផ្ទៃក្នុង របស់ក្រុមអ្នកប្រើប្រាស់ព្រៃឈើនៅតែបន្តជាអាទិភាពក្នុងដំណើរការផ្លាស់ប្តូរសម្រាប់ប្រទេសនេប៉ាល់ ។






ក្រុមរបស់ប្រទេសនេប៉ាល់បានកំណត់នូវការប្តេជ្ញាចិត្តនៅក្នុងវេទិកានេះដូចជា៖

- សម្របសម្រួលឱ្យមានការពិនិត្យឡើងវិញនូវការប្រឹក្សាយោបល់ពីគោលនយោបាយប្រកបដោយតម្លាភាព ដើម្បីជម្រុញ ឱ្យមានការផ្លាស់ប្តូរចំពោះសហគ្រាស ទាកទងទៅនឹងសហគមន៍ព្រៃឈើ
- បង្កើន និងចងក្រងឯកសារស្តីពីភាពជោគជ័យរបស់សហគ្រាសសហគមន៍ព្រៃឈើនៅកម្រិតតំបន់ទេសភាព
- ភ្ជាប់ទំនាក់ទំនងរវាងសហគ្រិននៅមូលដ្ឋាន និងវិស័យឯកជន ទៅនឹងប្រព័ន្ធព័ត៌មានទីផ្សារ
- ពង្រឹងភាពជាអ្នកដឹកនាំរបស់ក្រុមអ្នកប្រើប្រាស់ព្រៃសហគមន៍ ក្នុងអភិបាលកិច្ចព្រៃឈើតាមរយៈការ កសាងសមត្ថភាពដល់ស្ត្រី និងក្រុមសម្លេងភាគតិច។




# ប្រទេសថៃ

មលដល់ពេលនេះ ប្រទេសថៃមានដីព្រៃសហគមន៍ប្រហែល ១,២ លានហិកតា។ ដោយសារតែក្របខណ្ឌគតិយុត្តមិនទាន់បានផ្តល់ឱកាសទទួលស្គាល់តំបន់គ្រប់គ្រងសហគមន៍នៅឡើយ ដូចនេះមួយភាគធំនៃតំបន់ទាំងនេះធ្វើឡើងដោយមិនទាន់មានកិច្ចព្រមព្រៀងជាមួយរដ្ឋាភិបាលនៅឡើយ។ យន្តការកាត់បន្ថយការបញ្ចេញឧស្ម័នបណ្តាលមកពីការបាត់បង់ និងការរេចរឹលព្រៃឈើ (REDD+) ថ្មីៗនេះបានផ្តល់ឱកាសក្នុងការគៀងគរការគាំទ្រដល់សហគមន៍ព្រៃឈើ និងរដ្ឋាភិបាល បានទទួលស្គាល់ផ្ទៃដីសហគមន៍កាន់តែច្រើនឡើង។

ក្រុមអ្នកចូលរួមរបស់ប្រទេសថៃបានចាត់អាទិភាពនៃការផ្លាស់ប្តូរមួយចំនួន ដែលចាំបាច់ក្នុងការបង្កើនសហគមន៍ព្រៃឈើ ដោយរួមបញ្ចូលទាំងការចូលរួមពិនិត្យឡើងវិញនូវក្របខណ្ឌគតិយុត្ត និងគោលនយោបាយ ការផ្លាស់ប្តូរទៅរកសហគ្រាសសហគមន៍ព្រៃឈើ ដែលនេះតម្រូវឱ្យបង្កើនការទំនាក់ទំនងជាមួយវិស័យឯកជន និងការគាំទ្របច្ចេកទេសសហគ្រាស ទៅដល់សហគមន៍ពីសំណាក់នាយកដ្ឋានព្រៃឈើ ។




ការប្តេជ្ញាចិត្តសម្រាប់ពេលបីឆ្នាំទៅមុខ៖

- ធ្វើផែនទីសហគមន៍ព្រៃឈើដែលមានស្រាប់  និងធនធានក្នុងមូលដ្ឋាន
- ពង្រីកមូលដ្ឋានផលិតផលសហគមន៍ព្រៃឈើ ដោយរួមទាំងការពង្រឹងសមត្ថភាពនៃសង្វាក់ផលិតកម្មនិង អត្តសញ្ញាណផលិតផល
- បង្កើនភាពជាដៃគូឱ្យបានកាន់តែខ្លាំងឡើង ដើម្បីលើកកម្ពស់ការពង្រីកសហគមន៍ព្រៃឈើ និងការអភិវឌ្ឍសហគ្រាស់ពាក់ព័ន្ធ  ដោយរួមបញ្ចូលទាំងការភ្ជាប់ទំនាក់ទំនងប្រកបដោយប្រសិទ្ធភាពរបស់វិស័យឯកជន។




# ប្រទេសវៀតណាម

គិតត្រឹមឆ្នាំ ២០១៣ ផ្ទៃដីព្រៃឈើជាង ២០% នៃផ្ទៃដីព្រៃឈើសរុបរបស់ប្រទេសវៀតណាម ត្រូវបានដាក់ឱ្យទៅជាតំបន់សហគមន៍ព្រៃឈើ ក្រោមការគ្រប់គ្រងរបស់សហគមន៍មូលដ្ឋាន។ តែទោះបីជាយ៉ាងណាក៏ដោយក៏ផ្ទៃដីជាមធ្យមមានត្រឹមតែ ១ ទៅ ១,៥ ហិកតាប៉ុណ្ណោះក្នុងមួយគ្រួសារដែលនេះនៅមានទំហំតូចនៅឡើយ។ ទោះបីជាសហគមន៍ព្រៃឈើ ត្រូវបានទទួលស្គាល់ក្នុងច្បាប់គ្រប់គ្រងព្រៃឈើក៏ដោយ ក៏លក្ខខណ្ឌគតិយុត្ត នៃសហគមន៍ទាក់ទងទៅនឹងការគ្រប់គ្រងព្រៃឈើជាក់ស្តែងនៅតែមានភាពមិនច្បាស់លាស់ ព្រមទាំងការរៀបចំផែនការ និងនិតិវិធីដែលផ្តល់ឱកាសដល់ការគ្រប់គ្រង និងការប្រើប្រាស់ព្រៃឈើជាក់ស្តែង នៅមានភាពស្មុកស្មាញនៅឡើយ។ អ្នកចូលរួមក្នុងវេទិកាថ្នាក់តំបន់លើកទី ៣ មកពីប្រទេសវៀតណាម ចង់ឃើញការពង្រីកបន្ថែមទៀតនូវការផ្តល់សេវាកម្មពីរដ្ឋាភិបាលទៅកាន់សហគមន៍ទំនាក់ទំនងទៅនឹងការគ្រប់គ្រងព្រៃឈើ និងដើម្បីបង្កើតប្រាក់ចំណូលតាមរយៈការអភិវឌ្ឍសង្វាក់ផលិតកម្មនៃផលិតផលសហគមន៍ព្រៃឈើ។




ការប្តេជ្ញាចិត្តសម្រាប់ពេលបីឆ្នាំទៅមុខ៖

- សម្របសម្រួល និងជម្រុញការកែលម្អរច្បាប់ព្រៃឈើ  ដើម្បីលើកកម្ពស់សិទ្ធរបស់សហគមន៍មូលដ្ឋាន
- បញ្ចូលសហគមន៍ព្រៃឈើទៅក្នុងដំណើរការរៀបចំផែនការប្រើប្រាស់ដីធ្លីដោយមានការចូលរួមនិងដំណើរការបែងចែកដីធ្លី
- លើកកម្ពស់កំណែទម្រង់ស្ថាប័ន និងការកសាងសមត្ថភាព  ដើម្បីបង្កើតស្ថាប័នជំនាញក្នុងរដ្ឋាបាលព្រៃឈើប្រទេសវៀតណាមដើម្បីឱ្យមានការទទួលខុសត្រូវច្បាស់លាស់ចំពោះសហគមន៍ព្រៃឈើ
- រក្សា និងពង្រីកបន្ថែមទៀតនូវតំបន់សាកល្បង  និងចងក្រងឯកសារស្តីពីការអនុវត្តគំរូរបស់សហគមន៍។




# ប្រទេសម៉ាឡេស៊ី

បើទោះបីជាសកម្មភាពព្រៃឈើសង្គម ត្រូវបានគេអនុវត្តនៅក្នុងមូលដ្ឋានក៏ដោយ ក៏មិនទាន់មានការទទួលស្គាល់ជាយុទ្ធសាស្ត្រសំខាន់មួយនៅឡើយ ក្នុងការរួមចំណែកលុបបំបាត់ភាពក្រីក្រ និងការអភិវឌ្ឍជាតិ។ សហគមន៍ដែលមានទំនាក់ទំនងទៅនឹងព្រៃឈើសង្គម ចាំបាច់ត្រូវពង្រីកបណ្តាញរបស់ខ្លួន និងចូលរួមចំណែកទៅក្នុងវេទិកាពិភាក្សារៀបចំគោលនយោបាយដែលរាល់បញ្ហា និងឧបសគ្គនានារបស់ពួកគេត្រូវបានដាក់បញ្ចូលទៅក្នុងការរៀបចំគោលនយោបាយ។

ការប្តេជ្ញាចិត្តរបស់ក្រុមប្រទេសម៉ាឡេស៊ីរួមមាន៖

- ការពិនិត្យឡើងវិញ នូវគោលនយោបាយសហគមន៍ព្រៃឈើ ដោយភ្ជាប់ទៅកម្រិតសហគមន៍
- កសាងបណ្តាញឱ្យកាន់តែរឹងមាំឡើង រវាងសហគមន៍ និងភាគីពាក់ព័ន្ធផ្សេងៗទៀត
- ផ្តល់ការបណ្តុះបណ្តាលជំនាញស្តីពីសហគមន៍ព្រៃឈើ ទៅមន្ត្រីរដ្ឋាភិបាលមូលដ្ឋាន
- បន្តការយកចិត្តទុកដាក់ទៅលើសារៈសំខាន់របស់សហគមន៍ព្រៃឈើ តាមរយៈសកម្មភាពក្នុងមូលដ្ឋាន។




# ប្រទេសហ្វីលីពីន

គោលនយោបាយ និងក្របខណ្ឌគតិយុត្ត សម្រាប់សហគមន៍ព្រៃឈើ ត្រូវបានបង្កើតយ៉ាងពេញលេញដោយមានច្បាប់ និងគោលនយោបាយ ដែលធានាសុវត្ថិភាពសិទ្ធិកាន់កាប់ក្នុងរយៈពេល ២៥ ឆ្នាំ ទៅដល់សហគមន៍ណាដែលបានចុះបញ្ជីក្នុងប្រព័ន្ធ CBFM។ បច្ចុប្បន្ននេះ ផ្ទៃដីព្រៃចំនួន ១,៦ លានហិកតា ស្ថិតនៅក្រោមការគ្រប់គ្រងដោយស្ថាប័នមូលដ្ឋានចំនួន ១.៩០០ ផ្សេងៗគ្នា។ កិច្ចព្រមព្រៀងគ្រប់គ្រងសហគមន៍ព្រៃឈើ ជម្រុញឱ្យមានការប្រើប្រាស់ព្រៃឈើប្រកបដោយនិរន្តរភាពពីសំណាក់សហគមន៍។ ក្រុមអ្នកចូលរួមមកប្រទេសហ្វីលីពីន ចង់ឃើញចំនួនសហគមន៍បន្ថែមទៀតទទួលបានកិច្ចព្រមព្រៀងក្នុងកំលុងពេលបីឆ្នាំខាងមុខ។

ក្រុមរបស់ប្រទេសហ្វីលីពីនបានធ្វើការប្តេជ្ញាចិត្តដូចជា៖

- ស្វែងរកការគាំទ្រលើក្របខណ្ឌគតិយុត្ត និងគោលនយោបាយដែលបានកែសម្រួល “The SFM Bill” តាមរយៈរដ្ឋសភា ដោយលើកឡើងនូវតម្រូវការសម្រាប់ការលើកកម្ពស់ផែនការប្រើប្រាស់ដីព្រៃឈើ និងផលិតផលព្រៃឈើ
- រៀបចំ និងអនុម័ត ទៅលើការទូទាត់សម្រាប់សេវាកម្មបរិស្ថាន (Payment for Environmental Services)
- បន្តការលើកកម្ពស់ការគ្រប់គ្រងសហគមន៍ព្រៃឈើ ដោយបង្កើនវិសាលភាពព្រៃឈើ និងកិច្ចព្រមព្រៀងដែលអនុញ្ញាតិឱ្យសហគមន៍ប្រើប្រាស់ផលិតផលពីព្រៃឈើ។


Pathways to...
Increasing forest area under community management
Strengthening the active control of communities over their forests
Ensuring that institutions are able to effectively implement Community Forestry laws in country

# សេចក្តីសន្និដ្ឋាន និងជំហានបន្ទាប់

អ្នកចូលរួមក្នុងវេទិកាថ្នាក់តំបន់លើកទី៣ ស្តីពីមនុស្ស និងព្រៃឈើ ក្នុងរយៈពេល ០២ ថ្ងៃនេះបានចែករំលែកចំណេះដឹង និងបទពិសោធន៍របស់ពួកគេ ដោយបានកំណត់នូវប្រធានបទរួមមួយប្រចាំតំបន់ ដើម្បីពង្រឹងតួនាទីសំខាន់នៅក្នុងសហគមន៍ព្រៃឈើ និងការប្តេជ្ញាចិត្ត ដែលគាំទ្រដោយភាគីពាក់ព័ន្ធ និងផែនការសកម្មភាពប្រទេសរួមគ្នា ហើយកំណត់នូវសកម្មភាពច្បាស់លាស់ដែលនឹងត្រូវអនុវត្តជាចំបាច់ដោយភាគីពាក់ព័ន្ធនានា។

ប្រធានបទរួមប្រចាំតំបន់មួយចំនួន បានកំណត់ឡើងដើម្បីជម្រុញការពង្រឹងសហគមន៍ព្រៃឈើ រួមមានសុវត្ថិភាពសិទ្ធកាន់កាប់ព្រៃឈើ បញ្ហាប្រឈមក្នុងការអនុវត្តគោលនយោបាយ ការរួមបញ្ចូលគ្នានូវតំបន់តូចៗទៅក្នុងកម្រិតតំបន់ទេសភាព ការផ្សារភ្ជាប់សហគមន៍ព្រៃឈើទៅនិងវិស័យផ្សេងៗ ការបញ្ចូលសហគមន៍ព្រៃឈើនៅក្នុងរបៀបវារៈសកល និងការទទួលបានផលប្រយោជន៍សេដ្ឋកិច្ច ពីការធ្វើពាណិជ្ជកម្មផលិតផល និងសេវាកម្មពីសហគមន៍ព្រៃឈើ។

ការប្តេជ្ញាចិត្ត និងតួនាទីដែលនឹងត្រូវអនុវត្តន៍ដើម្បីពង្រឹងសហគមន៍ព្រៃឈើពីសំណាក់ភាគីពាក់ព័ន្ធដែលរួមមាន រដ្ឋាភិបាលថ្នាក់កណ្តាល ក្រសួងជំនាញ វិស័យឯកជន អង្គការអន្តរជាតិ អ្នកស្រាវជ្រាវ គ្រឹះស្ថានឧត្តមសិក្សា ប្រព័ន្ធផ្សព្វផ្សាយ សង្គមស៊ីវិល និងសហគមន៍មូលដ្ឋាន ក៏ត្រូវបានកំណត់ឡើងដោយក្រុមភាគីពាក់ព័ន្ធនៃប្រទេសនីមួយៗ។

វេទិកានេះបានបញ្ចប់ទៅដោយសម្រេចបាននូវការបង្កើតផែនការសកម្មភាពប្រទេសរួមគ្នា ពីសំណាក់ប្រទេសនីមួយៗ។ ផែនការសកម្មភាពនេះ បង្កើតឡើងដោយអ្នកចូលរួមមកពីប្រទេសកម្ពុជា ឥណ្ឌូនេស៊ី ឡាវ មីយ៉ាន់ម៉ា ថៃ វៀតណាម ចិន នេប៉ាល់ ម៉ាឡេស៊ី និងប្រទេសហ្វីលីពីន។ ផែនការនេះសង្កត់ធ្ងន់ទៅលើសកម្មភាពចំបាច់មួយចំនួនដែលត្រូវអនុវត្ត ដើម្បីជម្រុញវឌ្ឍនភាព ផ្តើមចេញពីស្ថានភាពបច្ចុប្បន្ន និងអ្នកពាក់ព័ន្ធ ព្រមទាំងសកម្មភាពអាទិភាពដែលត្រូវអនុវត្តក្នុងរយៈពេលបីឆ្នាំបន្ទាប់។

តំណាងដែលមកពី APFNet បណ្តាញសង្គមព្រៃឈើអាស៊ាន (ASFN) និងទីភ្នាក់ងារជប៉ុនសហប្រតិបត្តិការអន្តរជាតិ(JICA) បានធ្វើការសង្ខេបដោយឆ្លុះបញ្ចាំងពីលទ្ធផល និងអនុសាសន៍នៅក្នុងវេទិកានេះ។

លោក Zuofeng Zhuang ប្រធានគ្រប់គ្រងផែនការ នៃលេខាធិការដ្ឋាន APFNet បានបញ្ជាក់ថាវេទិកានេះជាឱកាសដ៏សំខាន់មួយក្នុងការបញ្ចេញមតិរបស់ភាគីពាក់ព័ន្ធ។ លោកបានកត់សម្គាល់ទៀតថា សិក្ខាកាមទាំងអស់បានចូលរួមយ៉ាងសកម្មនៅគ្រប់ផ្នែកទាំងអស់ និងបានរួមចំណែកក្នុងការផ្តល់យោបល់ និងអនុសាសន៍ជាច្រើន។ លោកបានសង្ខេបថា អាទិភាពចម្បងដែលត្រូវអនុវត្តរួមមាន ការកសាងសមត្ថភាពដើម្បីពង្រឹងសហគមន៍ព្រៃឈើ ការបញ្ជ្រាបសហគមន៍ព្រៃឈើទៅក្នុងផែនការជាតិ ដើម្បីធានាបានថាសហគមន៍ទទួលបានការគាំទ្រពីរដ្ឋាភិបាលរបស់ពួកគេ ទាំងបច្ចេកទេស និងហិរញ្ញវត្ថុ ដើម្បីអនុវត្តសកម្មភាពនានាក្នុងគោលបំណងលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាជនមូលដ្ឋាន និងការធ្វើពាណិជ្ជកម្មផលិតផល និងសេវាកម្មរបស់សហគមន៍ព្រៃឈើ ។

លោក Sugeng Marsudiarto នាយករង នៃនាយកដ្ឋានអភិវឌ្ឍន៍សហគមន៍ព្រៃឈើ នៃក្រសួងរុក្ខាប្រមាញ់ ប្រទេសឥណ្ឌូនេស៊ី (ជាតំណាងលោក Thong Eth Phayvanh នាយក ASFN) បានយល់ឃើញថា វេទិកានេះផ្តល់ឱកាសដ៏សំខាន់មួយសម្រាប់អ្នកចូលរួមដើម្បីចែករំលែកគំនិតយោបល់ស្តីពីការអភិវឌ្ឍសហគមន៍ព្រៃឈើ នាពេលអនាគត។ លោកបានធ្វើការបញ្ជាក់សារជាថ្មីពីការប្តេជ្ញាចិត្តរបស់ ASFN ក្នុងការភ្ជាប់ទំនាក់ទំនងជាមួយអង្គការសង្គមស៊ីវិល ក្នុងការអភិវឌ្ឍសហគមន៍ព្រៃឈើ ព្រមទាំងអាទិភាពក្នុងការកាត់បន្ថយភាពក្រីក្រ និងកាត់បន្ថយការបំភាយឧស្ម័នពីការបាត់បង់ និងរេចរឹលព្រៃឈើ តាមរយៈក្រមខណ្ឌការងាររបស់ ASFCC។ លោកក៏បានជម្រុញឱ្យអ្នកចូលរួមទាំងអស់អនុវត្តនូវរាល់ការប្តេជ្ញាចិត្ត ដែលបានលើកឡើងនៅក្នុងវេទិកានេះ។

លោក Kenichi Shishido នាយករងនៃនាយកដ្ឋានបរិស្ថានសាកល ប្រចាំអង្គការ JICA បានបញ្ជាក់សាជាថ្មីថា វេទិកានេះបានផ្តល់នូវបទពិសោធន៍ថ្មីមានដល់អ្នកចូលរួមទាំងអស់ បានយល់ពីទស្សនៈផ្សេងៗពីសំណាក់ភាគីពាក់ព័ន្ធ។ លោកបានចាប់អារម្មណ៍យ៉ាងខ្លាំងនៅវគ្គចុងក្រោយនៃវេទិកានេះ ដែលតម្រូវឱ្យប្រទេសនីមួយៗកំណត់នូវការប្តេជ្ញាចិត្តរបស់ពួកគេ។ លោក Kenichi Shishido ក៏បានផ្តល់នូវអនុសាសន៍សម្រាប់វេទិកានេះថា អ្នកចូលរួមលើកក្រោយអាចចែករំលែកនូវវឌ្ឍនភាព ការផ្លាស់ប្តូរ និងសមិទ្ធផលសម្រេចបានពីការប្តេជ្ញាចិត្តរបស់ប្រទេសនីមួយៗ និងលើកឡើងនូវគម្រោងជោគជ័យនានា។

លោក Tint Lwin Thaung នាយកប្រតិបត្តិរបស់អង្គការ RECOFTC បានធ្វើសេចក្តីសន្និដ្ឋានថា៖ "វេទិកាលើកទី ៣ នេះបានបង្កើតឱ្យមានបរិយាកាសគាំទ្រដល់អ្នកចូលរួមទាំងអស់ធ្វើឱ្យមានភាពសកម្ម។ វេទិកានេះសម្រេចបានផ្លែផ្កាជាច្រើន ដោយអ្នកចូលរួមទាំងអស់បានរួមចំណែក និងប្រាស្រ័យទាក់ទងគ្នាទៅវិញទៅមកយ៉ាងរស់រវើក។ ខ្ញុំជឿជាក់ថាយើងទាំងអស់គ្នាបានទទួលចំណេះដឹងជាច្រើន និងជាពិសេសគឺយើងអាចដឹងថា អ្នកទាំងអស់គ្នាបានប្តេជ្ញាចិត្ត ដើម្បីលើកកម្ពស់សហគមន៍ព្រៃឈើតាមរយៈសកម្មភាពនៅថ្នាក់ជាតិ"។

ក្រោយពីវេទិកានេះ គេបានធ្វើការវិភាគនៃទម្រង់វាយតម្លៃដែលបង្ហាញឱ្យឃើញថាអ្នកចូលរួមទាំងអស់បានទទួលនូវការយល់ដឹងកាន់តែប្រសើរឡើងពីតម្រូវការជាអាទិភាពក្នុងតំបន់ ដើម្បីពង្រឹងសហគមន៍ព្រៃឈើ (សិទ្ធិកាន់កាប់ ការប្រកបរបរចិញ្ចឹមជីវិត ការចូលរួមរបស់សហគមន៍មូលដ្ឋាន) និងចំណេះដឹងអំពីស្ថានភាពបច្ចុប្បន្ន និងឧបសគ្គនានា ដែលសហគមន៍ព្រៃឈើបានជួបប្រទះនៅក្នុងប្រទេសនីមួយៗ។ អ្នកចូលរួមទាំងអស់បានប្តេជ្ញាចិត្តក្នុងការពង្រឹងសហគមន៍ព្រៃឈើ។ សកម្មភាពដែលអ្នកចូលរួមម្នាក់ៗបានលើកឡើងត្រូវបានចាត់ជាបីប្រភេទដូចជាៈ

**ការស្រាវជ្រាវ ការទំនាក់ទំនង និងការស្វែងរកការគាំទ្រៈ**

*"ចែកចាយព័ត៌មានទៅដល់ប្រព័ន្ធផ្សព្វផ្សាយ និងសាធារណៈជន ដើម្បីស្វែងរកការគាំទ្រពីសំណាក់អ្នកបង្កើតគោលនយោបាយ និងអ្នកធ្វើការសម្រេចចិត្ត ព្រមទាំងដើម្បីផ្តល់នូវឯកសារគោលនយោបាយ និងឯកសារពាក់ព័ន្ធផ្សេងៗទៀត"។*

*"ចងក្រងឯកសារស្តីអំពីសហគមន៍ព្រៃឈើដែលមានស្នាដៃល្អ ដើម្បីប្រើប្រាស់ជាឧបករណ៍តស៊ូមតិ និងស្វែងរកការគាំទ្រពីសំណាក់ភាគីពាក់ព័ន្ធក្នុងការអនុវត្តសហគមន៍ព្រៃឈើ"។*

*"ធ្វើការសិក្សាស្រាវជ្រាវទៅលើគំរូសហគ្រាសសហគមន៍ព្រៃឈើ និងការងារគំរូ" ។*

**ការចងក្រងបណ្តាញ និងសកម្មភាពនៅមូលដ្ឋានៈ**

*"លើកយកគំនិតដែលទទួលបានពីវេទិកាថ្នាក់តំបន់នេះ ទៅបង្ហាញដល់ភាគីពាក់ព័ន្ធដ៏ទៃទៀតក្នុងវេទិកាថ្នាក់ជាតិ"។*

*"យកគំនិតដែលបានមកពីវេទិកាថ្នាក់តំបន់នេះ ទៅដាក់បញ្ចូលទៅក្នុងផែនការសកម្មភាពសហគមន៍ព្រៃឈើជាតិ"។*

*"លើកកម្ពស់ការប្តេជ្ញាចិត្តរបស់ភាគីពាក់ព័ន្ធទៅលើការអភិវឌ្ឍសហគមន៍ព្រៃឈើតាមរយៈក្រុមការងារថ្នាក់ជាតិ និងក្រុមការងារថ្នាក់មូលដ្ឋាន "។*



**ការកសាងសមត្ថភាព**

*"បង្កើតកម្មវិធីអភិវឌ្ឍន៍សមត្ថភាពសហគមន៍ព្រៃឈើឱ្យកាន់តែមានប្រសិទ្ធិភាពជាងមុន" ។*

*"ប្រើប្រាស់ចំណេះដឹងដែលទទួលបានមកពីវេទិកាថ្នាក់តំបន់ ដើម្បីពង្រឹងដល់ការកសាងមេរៀនសហគមន៍ព្រៃឈើ និងកម្មវិធីបណ្តុះបណ្តាលនៅក្នុងមជ្ឈមណ្ឌលបណ្តុះបណ្តាលរបស់ខ្ញុំ"។*



គេក៏បានផលិតឯកសារវីដេអូដោយតម្រូវឱ្យអ្នកចូលរួមក្នុងវេទិកានេះឆ្លើយនឹងសំណួរចំនួន ៤ គឺ ៖ ហេតុអ្វីបានជាសហគមន៍ព្រៃឈើមានសារៈសំខាន់? តើមានបញ្ហាសំខាន់ៗអ្វីខ្លះដែលកើតមានឡើងក្នុងសហគមន៍ព្រៃឈើនាពេលបច្ចុប្បន្ន និងអនាគត? តើវេទិកានេះ មានប្រយោជន៍អ្វីខ្លះ? តើគេចំបាច់ត្រូវធ្វើអ្វីខ្លះ ដើម្បីជម្រុញសហគមន៍ព្រៃឈើបន្ថែមទៀតបន្ទាប់ពីវេទិកានេះ?

មានប្រព័ន្ធផ្សព្វផ្សាយក្នុងតំបន់ជាច្រើនស្ថាប័ន បានចូលរួមយកព័ត៌មានក្នុងវេទិកាថ្នាក់តំបន់លើកទី ៣ នេះ។ ប្រព័ន្ធផ្សព្វផ្សាយក្នុងប្រទេសថៃមានដូចជា ទូរទស្សន៍ប៉ុស្តិ៍លេខ ៣ ទូរទស្សន៍ប៉ុស្តិ៍លេខ ៧ ទូរទស្សន៍ប៉ុស្តិ៍លេខ ៩ កាសែត Krungthep Turaki កាសែត The Nation កាសែត Thai PBS កាសែត Bangkok Post កាសែត Khao Sod និងទូរទស្សន៍ KT TV។ ក្រៅពីនេះមានសារព័ត៌មានក្នុងតំបន់ជាច្រើនទៀតបានរាយការណ៍ពីព្រឹត្តិការណ៍នេះដូចជា កាសែត the Phnom Penh Post របស់ប្រទេសកម្ពុជា កាសែត Vietnamenet របស់វៀតណាម កាសែត Myanmar Times របស់មីយ៉ាន់ម៉ា និង The Green China របស់ប្រទេសចិន។

ផ្តើមចេញពីវេទិកាថ្នាក់តំបន់លើកទី ៣ ស្តីពីមនុស្ស និងព្រៃឈើនេះ ប្រទេសនីមួយៗដូចជា ប្រទេសកម្ពុជា ឥណ្ឌូនេស៊ី ឡាវ មីយ៉ាន់ម៉ា ថៃ និងវៀតណាម នឹងរៀបចំវេទិកាថ្នាក់ជាតិក្នុងប្រទេសរៀងៗខ្លួន។ វេទិកាថ្នាក់ជាតិទាំងនេះធ្វើឡើងក្នុងគោលបំណងដើម្បីឱ្យមានការចូលរួមកាន់តែទូលំទូលាយ និងពង្រឹងភាពជាម្ចាស់របស់ភាគីពាក់ព័ន្ធមូលដ្ឋានដើម្បីការអភិវឌ្ឍន៍ និងការអនុវត្តនាពេលអនាគតទៅលើផែនការសកម្មភាព និងការកំណត់អាទិភាពទៅលើសហគមន៍ព្រៃឈើរបស់ពួកគេ។

គោលបំណងរបស់វេទិកាថ្នាក់ជាតិរួមមាន៖

- វាយតម្លៃពីវឌ្ឍនភាពរបស់សហគមន៍ព្រៃឈើក្នុងប្រទេសនីមួយៗ ដោយរួមទាំងការពិនិត្យឡើងវិញនូវឯកសារគោលនយោបាយ និងអនុសាសន៍ផ្សេងៗដែលមានស្រាប់ទាក់ទងទៅនឹងព្រៃឈើដូចជា គោលនយោបាយជាតិ បទបញ្ញត្តិនានា យុទ្ធសាស្ត្រនានា ព្រមទាំងរបាយការណ៍ស្រាវជ្រាវរបស់ RECOFTC ស្តីពី៖ សហគមន៍ព្រៃឈើនៅក្នុងតំបន់អាស៊ី និងប៉ាស៊ីភិច៖ វិថីឆ្ពោះទៅរកការអភិវឌ្ឍ (Community Forestry in Asia and the Pacific: Pathway to inclusive development) និងឯកសារផ្សេងៗទៀត
- បង្កើនការប្តេជ្ញាចិត្តឱ្យបានខ្លាំងក្លា លើសហគមន៍ព្រៃឈើ ក្នុងចំណោមភាគីពាក់ព័ន្ធសំខាន់ៗតាមរយៈផែនការសម្មភាពប្រទេសរួមគ្នា
- ជម្រុញឱ្យមានសុខដុមនីយកម្មនៃយុទ្ធសាស្ត្រ និងកិច្ចខិតខំប្រឹងប្រែងនាពេលអនាគត ដោយបញ្ចូលក្រុមការងារថ្នាក់ជាតិដែលមានស្រាប់ក្នុងសហគមន៍ព្រៃឈើ និងវិស័យព្រៃឈើ ព្រមទាំងអន្តរវិស័យផ្សេងៗនៅក្នុងប្រទេស។

អនុសាសន៍ទាំងឡាយដែលបានលើកឡើងនៅក្នុងវេទិកានេះ និងជួយពង្រឹងការអភិវឌ្ឍបន្ថែមទៀតទៅលើកម្មវិធីអនុវត្តន៍ប្រចាំប្រទេសរបស់ RECOFTC។ វេទិកាថ្នាក់ជាតិ និងត្រូវធ្វើឡើងនៅដើមឆ្នាំ ២០១៤ ដែលនឹងមានការចូលរួមពីភាគីពាក់ព័ន្ធមកពីផ្នែកផ្សេងៗគ្នាដូចជា ស្ថាប័នរដ្ឋាភិបាល អង្គការ/សង្គមស៊ីវិល សហគមន៍មូលដ្ឋាន គ្រឹះស្ថានឧត្តមសិក្សា អង្គការអន្តរជាតិ ដៃគូអភិវឌ្ឍន៍ ប្រព័ន្ធផ្សព្វផ្សាយ និងវិស័យឯកជនផងដែរ។ វេទិកាថ្នាក់ជាតិ នឹងផ្តល់ឱកាស ជាពិសេសដល់ភាគីពាក់ព័ន្ធ ដែលមិនមានតំណាងចូលរួមក្នុងវេទិកាថ្នាក់តំបន់នេះដូចជាសហគមន៍មូលដ្ឋាន និងអង្គការមូលដ្ឋានជាដើម។



FLAG OF COMMITMENT
FOREST LAW WITH FULL RIGHTS
SAY YES
DEMONSTRATION OF CF MODELS
CAPACITY BUILDING FOR CF BOARD BY KEY PERSONS
SET UP DEPARTMENT belonged
PARTICIPATION LUP & LA FOR CF
VIETNAM
VN FOREST WHICH RESPONSIBLE FOR CF
MYANMAR
PARTNERSHIP AMONG STAKE HOLDER!
LAOS
GOV
DONOR
COMM
CF
CAMBODIA
POLICY
CF PA FI
NTFPs
NEPAL
WELL MANAGED FOREST
MAN
WOMEN
STREAM
GOOD PRODUCT = PROFIT
SUSTAINABLE FOREST MANAGEMENT
STRENGTHEN CF NETWORK
PHILIPPINE
CF STAKE HOLDERS
50 MORE CBFMA
TO COVER
5.000 ha MORE FOREST!
MALAYSIA
Community



CHINA
CF
STAKE HOLDERS
GIVE TECH SUPPORTS
WORK WITH LOCAL COMMUNITIES
POLICY & LAW
community forestry
CAPACITY BUILDING
STAKEHOLDER
INDONESIA
STAKEHOLDERS / PARTNERS HAND IN HANDS IN CF
MUNITY
GOVT
CSOs
PARTNERSHIP
GOOD FOREST
GOOD PRODUCT
GOOD INCOME
FOOD SECURITY
HAPPY PEOPLE
THAILAND
FOREST
COMMUNITY
RECOFTC
GOVT.
COMMUNITIES
NGE IN COMMUNITY
T SHOULD BE A
NCE OF COMMUNITY &
TO GET WIN-WIN
TION, SO EVERYBODY HAPPY!
forest
PRIVATE SECTOR
DONORS
CSO
MEDIA
ACADEMICS
change/balance

THE CENTER FOR
PEOPLE AND FORESTS

RECOFTC

RECOFTC's mission is to enhance capacities for stronger rights, improved governance and fairer benefits for local people in sustainable forested landscapes in the Asia and the Pacific region.

RECOFTC holds a unique and important place in the world of forestry. It is the only international not-for-profit organization that specializes in capacity development for community forestry. RECOFTC engages in strategic networks and effective partnerships with governments, nongovernmental organizations, civil society, the private sector, local people and research and educational institutes throughout the Asia-Pacific region and beyond. With over 25 years of international experience and a dynamic approach to capacity development – involving research and analysis, demonstration sites and training products – RECOFTC delivers innovative solutions for people and forests.

RECOFTC – The Center for People and Forests
P.O. Box 1111
Kasetsart Post Office
Bangkok 10903, Thailand
Tel (66-2) 940-5700
Fax (66-2) 561-4880
info@recoftc.org
www.recoftc.org

Printed on recycled paper

Norad

Schweizerische Eidgenossenschaft
Confédération suisse
Confederazione Svizzera
Confederaziun svizra

Swiss Agency for Development
and Cooperation SDC

SWEDEN